ក្រសួងមហាផ្ទៃ

ព្រះរាជាណាចក្រកម្ពុជា

# ការអនុវត្តច្បាប់ស្តីពីការការពារ កុមារនិងជនងាយរងគ្រោះ (LEAP)

# ក្របខ័ណ្ឌយុទ្ធសាស្ត្រ

អ្នកសម្របសម្រួលៈ

**Lourdes Autencio**
**Christian Guth**

ខែកញ្ញា ឆ្នាំ២០១០

# អក្សរកាត់

| | |
|---|---|
| ARTIP | គម្រោងស្តីពីការជួញដូរមនុស្សប្រចាំតំបន់អាស៊ី |
| AHTJP | គំរោងជំនួយសំរាប់សកម្មភាពប្រឆាំងការជួញដូរមនុស្ស និងការការពារអនីតិជន |
| CCJAP | គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា |
| CNP | នគរបាលជាតិកម្ពុជា |
| CNCC | ក្រុមប្រឹក្សាជាតិកម្ពុជាសម្រាប់កុមារ |
| IJM | បេសកកម្មយុត្តិធម៌អន្តរជាតិ |
| IOM | អង្គការទេសន្តរប្រវេសន៍អន្តរជាតិ |
| LEASETC | ការអនុវត្តច្បាប់ប្រឆាំងនឹងអំពើធ្វើអាជីវកម្មផ្លូវភេទ ការរំលោភផ្លូវភេទ និងការជួញដូរកុមារ |
| LEAP | ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់កម្មវិធីស្តីពីការជម្រុញការអនុវត្តន៍ច្បាប់ការពារកុមារ និងជនងាយរងគ្រោះ |
| MoH | ក្រសួងសុខាភិបាល |
| MoI | ក្រសួងមហាផ្ទៃ |
| MoJ | ក្រសួងយុត្តិធម៌ |
| MoSAVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងស្តារយុវនីតិសម្បទា |
| MoT | ក្រសួងទេសចរណ៍ |
| MoWA | ក្រសួងកិច្ចការនារី |
| NFP | កងកម្លាំងនគរបាលជាតិ |
| NPGC | អគ្គស្នងការដ្ឋាននគរបាលជាតិ |
| NSDP | ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ |
| RS | យុទ្ធសាស្ត្រចតុកោណ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SISHA | ការស៊ើបអង្កេតសកម្មភាពសង្គម និងមនុស្សធម៌នៅអាស៊ីអាគ្នេយ៍ |
| STLS | គណៈកម្មាធិការដឹកនាំការបង្ក្រាបការជួញដូរ ការរត់ពន្ធ ការកេងប្រវ័ញ្ចពលកម្ម និងការកេងប្រវ័ញ្ចផ្លូវភេទលើស្ត្រី និងកុមារ |
| TAF | មូលនិធិអាស៊ី |
| TIPSE | ការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ |
| TSEAC | ការជួញដូរ ការកេងប្រវ័ញ្ច និងការរំលោភផ្លូវភេទលើកុមារ |
| TSEC | ការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ |
| UNICEF | មូលនិធិកុមាររបស់អង្គការសហប្រជាជាតិ |
| UNOCHR | ការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| WVC | អង្គការទស្សនៈពិភពលោកកម្ពុជា |

# តារាងមាតិកា


I. សេចក្តីផ្តើម ........................................ 6

II. សាទតារ ........................................ 9

III. បញ្ហាប្រឈម និងមេរៀនបទពិសោធន៍ ........................................ 12

IV. ផ្លូវឆ្ពោះទៅមុខ : ក្របខ័ណ្ឌយុទ្ធសាស្ត្រ ឆ្នាំ២០១១-២០១៥ ........................................ 16

ទស្សនវិស័យ: ........................................ 20

បេសកកម្ម ........................................ 21

គោលដៅទូទៅ ........................................

គោលដៅយុទ្ធសាស្ត្រទី១ ........................................ 21

គោលដៅយុទ្ធសាស្ត្រទី ២ ........................................

គោលដៅយុទ្ធសាស្ត្រទី ៣ ........................................

V. រចនាសម្ព័ន្ធចាត់តាំង និងភាពជាដៃគូ

រចនាសម្ព័ន្ធ LEASETC បច្ចុប្បន្ន ឆ្នាំ២០០០-២០១០ ........................................ 28

សំណើរចនាសម្ព័ន្ធ LEAP ឆ្នាំ២០១១-២០១៥ ........................................ 29

VI. ទស្សនៈទានស្តីពីក្របខ័ណ្ឌយុទ្ធសាស្ត្រ LEAP ........................................ 30

VII. ការរៀបចំផែនការយុទ្ធសាស្ត្រ LEAP ឆ្នាំ២០១១-២០១៥ ........................................ 34

ឧបសម្ព័ន្ធ ១ ........................................ 36

បញ្ជីកម្រងច្បាប់ដែលពាក់ព័ន្ធស្តីពីការការពារក្រុមងាយរងគ្រោះ និងជនរងគ្រោះ ដោយសារការរំលោភបំពាន អំពើហិង្សា និងអំពើធ្វើអាជីវកម្ម ........................................ 36

ឧបសម្ព័ន្ធ ២: ផែនការសកម្មភាព LEAP ឆ្នាំ ២០១១ ........................................

# សេចក្តីផ្តើម

ចាប់តាំងពីឆ្នាំ២០០០មក ក្រសួងមហាផ្ទៃ (MoI) បានអនុវត្តគម្រោងស្តីពី ការអនុវត្តច្បាប់ប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភផ្លូវភេទ និងការជួញដូរកុមារ (LEASETC) ដែលផ្តោតជាចម្បងលើការទប់ស្កាត់ និងការស៊ើបអង្កេតករណីនានាទាក់ទងនឹងការកេងប្រវ័ញ្ច និងការរំលោភផ្លូវភេទ ការជួញដូរ និងអំពើហឹង្សាក្នុងគ្រួសារទៅលើកុមារ និង ស្ត្រី ។ គំរោង LEASETC ត្រូវបានឧបត្ថម្ភជាចម្បងដោយ UNICEF, WVC, Terre des Hommes Netherlands និង Kamonohashi ។

យោងតាមអនុក្រឹត្យលេខ៤០ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០២ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន (AHTJP) ព្រមទាំងអង្គភាពជំនាញនៅក្នុងខេត្តទាំង ១៧ ត្រូវបានបង្កើតឡើង។ នាយកដ្ឋាននេះមានភារកិច្ចផ្តល់នូវសេវាជំនាញក្នុងវិស័យទប់ស្កាត់ និងបង្ក្រាបរាល់ទំរង់នៃអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ការរំលោភផ្លូវភេទ រូបអាសអាភាស និងអំពើហឹង្សាក្នុងគ្រួសារ។

LEASETC បានគាំទ្រដល់ការបណ្តុះបណ្តាលនគរបាលតាមកម្រិតនីមួយ (ស្នងការរង ប្រធានអង្គភាពអ្នកគ្រប់គ្រងថ្នាក់កណ្តាល នៅថ្នាក់ខេត្ត និងថ្នាក់ស្រុក) នៅក្នុងខេត្តចំនួន១៣។ ការបណ្តុះបណ្តាលបណ្តើរវៀនបណ្តើរត្រូវបានប្រគល់ជូននាយកដ្ឋាន AHTJP និងដល់មន្ត្រីនគរបាលដែលកំពុងបំរើការនៅវិស័យបច្ចេកទេសសំរាប់ការធ្វើសម្ភាសន៍កុមារ ការប្រមូលភ័ស្តុតាងនីតិវេជ្ជសាស្ត្រ ការស្រាវជ្រាវភ័ស្តុតាងតាមកុំព្យូទ័រ និងរបៀបរៀបចំអោយប្រសើរឡើងនូវសំណុំរឿងក្តីដែលត្រូវបញ្ជូនទៅតុលាការ។ នគរបាលក៏ទទួលបានការជួយឧបត្ថម្ភផងដែរនៅក្នុងការតាមដានរឿងក្តីស្តីពីការជួញដូរ និង ការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភសេពសន្ថវៈ ។

មូលដ្ឋានទិន្នន័យ និង ឧបករណ៍ ឬទម្រង់នានាសម្រាប់ការប្រមូលទិន្នន័យត្រូវបានបង្កើតឡើងដើម្បីពិនិត្យតាមដានចំនួនករណីដែលត្រូវបានរាយការណ៍ទាក់ទងនឹង TSEC និងចំនួននៃការឃាត់ខ្លួន ។ បណ្តាញទូរស័ព្ទទាន់ហេតុការណ៍ ២៤ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍ និងអង្គភាពឆ្លើយតបមួយត្រូវបានបង្កើតឡើងនៅក្នុងនាយកដ្ឋានស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ហើយបច្ចុប្បន្ននៅក្នុងនាយកដ្ឋាន AHTPJ និងត្រូវបានដំណើរការចាប់តាំងពីខែតុលាឆ្នាំ២០០០។ កាលពីពេលថ្មីៗនេះបណ្តាញទូរស័ព្ទទាន់ហេតុការណ៍ថ្នាក់ខេត្តត្រូវបានបង្កើតឡើងនៅក្នុងអង្គភាពខេត្តចំនួន៧។ ទាំងជនរងគ្រោះ គ្រួសាររបស់ពួកគេ និងតតិជនអាចរាយការណ៍អំពីករណីនានា ហើយពួកគេនឹងទទួលបានព័ត៌មានអំពីជម្រើសនានាទាក់ទងនឹងការបញ្ជូនជនរងគ្រោះ។

តាងនាមអោយក្រសួងមហាផ្ទៃ ខ្ញុំមានសេចក្តីសោមនស្សក្នុងការបង្ហាញអំពី *ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់កម្មវិធីស្តីពីការជម្រុញការអនុវត្តន៍ច្បាប់ការពារកុមារ និងជនងាយរងគ្រោះ (LEAP)* ។ ក្របខ័ណ្ឌនេះមានគោលបំណងដើម្បីជួយណែនាំ រៀបចំ និងសម្របសម្រួលការរៀបចំផែនការជាប្រព័ន្ធ ការអនុវត្តន៍ និងការ

វាយតម្លៃកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងមហាផ្ទៃនៅក្នុងការដោះស្រាយបញ្ហាទាក់ទងនឹងការជួញដូរ ការកេងប្រវ័ញ្ចផ្លូវភេទ ការកេងប្រវ័ញ្ចលើកម្លាំងពលកម្ម ការរំលោភផ្លូវភេទ អំពើហឹង្សាក្នុងគ្រួសារ ការប្រើគ្រឿងញៀន និងបញ្ហានានាប្រឈមកុមារទំនាស់និងច្បាប់។ ក្របខ័ណ្ឌនេះឆ្លុះបញ្ចាំងអំពីចំណេះដឹង និង ការយល់ដឹងបច្ចុប្បន្ន អំពីប្រភេទនិងកម្រិតនៃការកេងប្រវ័ញ្ចផ្លូវភេទ និងពលកម្ម និងការជួញដូរមនុស្ស អំពីដើមហេតុនៃបញ្ហា ឬកត្តានានាដែលបង្កឱ្យមានជាបញ្ហាទាំងនោះ អំពីដំណោះស្រាយដែលមាន ប្រសិទ្ធិភាព និងលទ្ធផលដែលចង់បាន និងផលប៉ះពាល់។ ក្របខ័ណ្ឌនេះក៏លើកឡើងផងដែរអំពីតម្រូវការក្នុងការវាយតម្លៃ អោយបានគ្រប់គ្រាន់ទៅលើកិច្ចខិតខំប្រឹងប្រែងរបស់យើង ដើម្បីឱ្យយើងអាចប្រើប្រាស់ចំណេះដឹង និងបទពិសោធន៍ថ្មីៗទាំងនោះបាន និង អាចធ្វើការកែលម្អជាបន្តបន្ទាប់ ។

យើងខ្ញុំជឿជាក់ថា រចនាសម្ព័ន្ធ និងអភិក្រមដែលចែងនៅក្នុងក្របខ័ណ្ឌនេះនឹងផ្តល់នូវវិធីមួយដែលសមហេតុផល និងមានលក្ខណៈជាប្រព័ន្ធ ថែមទាំងមានលក្ខណៈទូលំទូលាយ និងអាចបត់បែនបាន មាគ៌ាសំរាប់ការពិនិត្យមើលឡើងវិញ និងការផ្តល់ព័ត៌មានអំពីកិច្ចប្រឹងប្រែងរបស់យើងដើម្បីសម្រេចបាននូវគោលដៅ និង វត្ថុបំណងជាយុទ្ធសាស្ត្ររបស់ LEAP ឆ្ពោះទៅលុបបំបាត់ការជួញដូរមនុស្ស និងរាល់ទម្រង់ទាំងអស់នៃអំពើហឹង្សាផ្អែកលើយែនឌ័រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០១០

**ព្រុំ សុខា**

រដ្ឋលេខាធិការនិងជានាយកកម្មវិធី LEAP

ក្រសួងមហាផ្ទៃ

# I. សេចក្តីផ្តើម

**គម្រោង LEASETC**

*នៅពេលយើងចាប់ផ្តើមគម្រោង LEASETC យើងចាប់ផ្តើមពីបាតដៃទទេ ទោះបីជាមានការពិភាក្សាអំពីការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទកុមារ ការផ្តោតទៅលើការយល់ដឹងជាសាធារណៈក៏ដោយ ប៉ុន្តែមិនទាន់មានសកម្មភាពអ្វីឡើយ ។ មួយជំហានម្តងៗ* ***LEASETC*** *បានផ្តោតទៅលើការបណ្តុះបណ្តាលនគរបាលអំពីផ្នែកបច្ចេកទេសនៃប្រតិបត្តិការសំខាន់ៗ។ វាមិនត្រឹមតែការនិយាយ ការបង្កើនការយល់ដឹង ... ប៉ុណ្ណោះទេ សមត្ថភាពនគរបាលបានកែលម្អយ៉ាងច្រើនដើម្បីឆ្លើយតបទៅនឹងអំពើកេងប្រវ័ញ្ច និងការជួញដូរកុមារចាប់តាំងពីឆ្នាំ២០០០ ... ។ ខ្ញុំមានមោទនភាព និងនិយាយថា ទោះបីជា* ***LEASETC*** *មានទំហំតូចក៏ដោយ ក៏កម្លាំងចលករដែលបង្កើតឡើងដោយគម្រោងនេះមានភាពធំធេង ... ភាពជាម្ចាស់ការ គឺស្ថិតនៅលើនគរបាល មិនមែនរូបខ្ញុំទេ ... យើងនៅតែមានផ្លូវដ៏វែងដែលត្រូវដើរ ... ភាពជាម្ចាស់ការរបស់រាជរដ្ឋាភិបាល កម្ពុជាត្រូវតែរីកចម្រើនជាមួយភាពជាដៃគូរឹងមាំ ... និងគប្បីមានតុល្យភាពរវាងភាពជាម្ចាស់ការរបស់រដ្ឋាភិបាល និងភាពជា ដៃគូរបស់សង្គមស៊ីវិល ... ។*

***ឯកឧត្តម ព្រុំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ***

ក្រសួងមហាផ្ទៃបានដាក់ឱ្យអនុវត្តន៍**គម្រោងស្តីពីការអនុវត្តច្បាប់ប្រឆាំងនឹងអំពើធ្វើអាជីវកម្មផ្លូវភេទ និងការជួញដូរកុមារ (LEASTC)** នៅក្នុងឆ្នាំ២០០០ ដើម្បីឆ្លើយតបទៅនឹងរបាយការណ៍ដែលកាន់តែកើនឡើងអំពីការជួញដូរ និងអំពើធ្វើអាជីវកម្មផ្លូវភេទលើកុមារនៅក្នុងប្រទេសកម្ពុជា ។ គម្រោង LEASETC មានគោលបំណងចម្បងដើម្បីកែលម្អសមត្ថភាពរបស់នគរបាលជាតិកម្ពុជាក្នុងការស៊ើបអង្កេតករណីនៃអំពើធ្វើអាជីវកម្មផ្លូវភេទ និងការជួញដូរកុមារ ការសង្គ្រោះ ជនរងគ្រោះដោយសារអំពើជួញដូរ និងអំពើធ្វើអាជីវកម្មផ្លូវភេទ ការឃាត់ខ្លួនជនល្មើស ការស្រាវជ្រាវរកភ័ស្តុតាង និង រៀបចំបណ្តឹងសម្រាប់នាំជនល្មើសយកមកការកាត់ទោស ។ គម្រោងនេះឆ្លុះបញ្ចាំងអំពីរបៀបវារៈរបស់ក្រសួងមហាផ្ទៃដើម្បីបង្ក្រាបអំពើធ្វើអាជីវកម្មផ្លូវភេទ និងអំពើធ្វើអាជីវកម្មលើពលកម្ម កុមារ និង ស្ត្រី ស្របតាម "យុទ្ធសាស្ត្រចតុកោណ" ដែលបានលើកឡើងនៅក្នុងផែនការអភិវឌ្ឍយុទ្ធសាស្ត្រជាតិឆ្នាំ២០០៦-២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជា ។[១]

---

[១] "យុទ្ធសាស្ត្រចតុកោណ" របស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់កំណើន ការងារ សមធម៌ និងប្រសិទ្ធផល ត្រូវបានអនុម័តនៅឆ្នាំ២០០៤ ហើយកំពុងត្រូវបានដំណើរការនៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍជាតិផ្សេងៗ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ផែនការអភិវឌ្ឍយុទ្ធសាស្ត្រជាតិ ឆ្នាំ២០០៦-២០១០ ដែលត្រូវបានបន្តដល់ឆ្នាំ២០១៣ ។

គម្រោងនេះត្រូវបានអនុវត្តជាបីដំណាក់កាលចាប់ពីឆ្នាំ២០០០ ដល់ឆ្នាំ២០១០ ដោយសហការជាចម្បងជាមួយមូលនិធិកុមាររបស់អង្គការសហប្រជាជាតិ (UNICEF) និងអង្គការទស្សនៈពិភពលោកកម្ពុជា (World Vision Cambodia)។ នៅក្នុងតំណាក់កាលទី១ ជំនួយហិរញ្ញវត្ថុបានផ្តល់ដោយអង្គការអន្តរជាតិសំរាប់ទេសន្តរប្រវេសន៍ (International Organi- zation for Migration-IOM), អង្គការសង្គ្រោះកុមារ (Save the Chidren-CSF) ន័រវ៉េស និងការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (UNOCHR) ដែលបានផ្តល់ជំនួយហិរញ្ញវត្ថុក្នុងអំឡុងដំណាក់កាលទីមួយ ហើយក្នុងឆ្នាំ២០០៩-២០១០ ត្រូវបានឧបត្ថម្ភដោយ Terre des Hommes Netherlands និង Kamonohashi ។

ការវាយតម្លៃមួយដែលត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ២០០៩ បានរកឃើញថា ឥទ្ធិពលសំខាន់ៗបំផុតរបស់ LEASETC គឺការការពារបានប្រសើរជាងមុនចំពោះកុមារដែលរងគ្រោះដោយសារការរំលោភផ្លូវភេទ អំពើធ្វើអាជីវកម្ម ការជួញដូរ និង អំពើហិង្សាក្នុងគ្រួសារ។ បច្ចុប្បន្នជនរងគ្រោះត្រូវបានស្គាល់អត្តសញ្ញាណ មានការយកចិត្តទុកដាក់ និងផ្តល់ការការពារបានល្អប្រសើរជាងមុនតាមរយៈការពង្រឹងការអនុវត្តន៏ច្បាប់ ការងារសង្គមកិច្ច និងសង្គមស៊ីវិលដែលនាំអោយមានការទទួលស្គាល់កាន់តែច្រើនឡើងទៅលើតួនាទីដ៏លេចធ្លោពីការអនុវត្តន៏ច្បាប់ និងការងារសង្គមកិច្ចនេះ។

ជាមួយការគាំទ្ររបស់ LEASETC ក្រសួងមហាផ្ទៃបានបង្កើតនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនព្រមទាំងអង្គភាពជំនាញនៅក្នុងខេត្ត-ក្រុងចំនួន១០ ដែលមានមន្ត្រីនគរបាលជំនាញទទួលបានការបណ្តុះបណ្តាលចំនួនប្រមាណ២០០-២៥០នាក់។ ជាមួយនឹងការកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងរបាយការណ៏ស្តីពីការឃាត់ខ្លួន និង ការស៊ើបអង្កេតអំពីករណីនៃការជួញដូរ អំពើធ្វើអាជីវកម្មផ្លូវភេទ និងការរំលោភផ្លូវភេទកុមារ បន្ទាប់ពីបានចាប់ផ្តើមគម្រោង LEASETC រួចមក គម្រោងនេះត្រូវបានទទួលការកោតសរសើរពីមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៏អំពីភាពរីកចម្រើនដ៏ធំធេងដែលគម្រោងសម្រេចបាន ជាពិសេសការរួមចំណែករបស់គម្រោងក្នុងការបង្កើតអង្គភាពនគរបាលជំនាញលើកដំបូងនៅតំបន់អាស៊ីភាគគ្នេយ៏ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរ និង អំពើអាជីវកម្មផ្លូវភេទកុមារព្រមទាំងឥទ្ធិពលគួរអោយកត់សម្គាល់របស់គម្រោងទៅលើការងារនគរបាល។

ប្រព័ន្ធមូលដ្ឋានទិន្នន័យជាតិស្តីពីឧក្រិដ្ឋកម្មផ្លូវភេទមួយត្រូវបានបង្កើតឡើង និងផ្សារភ្ជាប់ជាមួយមូលដ្ឋានទិន្នន័យនគរបាលនៅក្នុងខេត្តចំនួន៧។ បណ្តាញទូរស័ព្ទទាន់ហេតុការណ៏របស់នគរបាលចំនួន៧ខ្សែដែលដំណើរការ ២៤ម៉ោងលើ២៤ម៉ោង សម្រាប់ការរាយការណ៏អំពីការជួញដូរ អំពើធ្វើអាជីវកម្ម និងការរំលោភផ្លូវភេទត្រូវបានបង្កើតឡើងដូចគ្នានេះដែរនៅក្នុងខេត្តចំនួន៧។ ទម្រង់បែបបទ/លិខិតបញ្ជាក់អំពីការធ្វើកោសល្យវិច្ច័យស្តង់ដារ

មួយដែលអនុញ្ញាតដោយក្រសួងសុខាភិបាល និងក្រសួងមហាផ្ទៃត្រូវបានអនុម័តសម្រាប់ការប្រើប្រាស់ជាភ័ស្តុតាងនៅក្នុងតុលាការជាតិ និងអន្តរជាតិ ។

ផ្អែកលើសមិទ្ធផលរបស់ LEASETC, ក្រសួងមហាផ្ទៃព្យាយាមបង្កើនប្រសិទ្ធិភាព និងប្រសិទ្ធិផលនៃសមត្ថភាពរបស់ខ្លួនក្នុងការអនុវត្តច្បាប់ និងការការពារក្រុមជនងាយរងគ្រោះនៅក្នុងប្រទេស។ ដូច្នេះ សម្រាប់ដំណាក់កាលបន្ទាប់ LEASETC កំពុងរៀបចំ និងដាក់ឈ្មោះជាថ្មីវិញថា **"ការលើកកំពស់ការអនុវត្តន៍ច្បាប់ស្តីពីការការពារកុមារ និងជនងាយរងគ្រោះ"** ឬជាភាសារអង់គ្លេសហៅថា "Law Enforcement Advancing Protection of Children and Vulnerable Persons- ឬហៅកាត់ថា **LEAP**។ **LEAP** នឹងដើរតួជាយន្តការមួយដែលសម្របសម្រួលគំនិតផ្តួចផ្តើមរបស់ក្រសួងមហាផ្ទៃក្នុងគោលបំណងពង្រឹងសមត្ថភាពអនុវត្តច្បាប់សម្រាប់ការការពារក្រុមជនងាយរងគ្រោះ ជាពិសេស គឺការបង្ក្រាបអំពើធ្វើអាជីវកម្មផ្លូវភេទ ការរំលោភផ្លូវភេទ អំពើហឹង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ អំពើធ្វើអាជីវកម្មតាមរយៈអាពាហ៍ពិពាហ៍ ការសេពគ្រឿងញៀន ការសុំកូនដើម្បីធ្វើអាជីវកម្ម និង បញ្ហានានាដែលប្រឈមជាមួយកុមារទំនាស់និងច្បាប់។

ក្រសួងមហាផ្ទៃ ស្ថាប័នផ្តល់មូលហិរញ្ញប្បទាន ដូចជាអង្គការ UNICEF និងអង្គការទស្សនៈពិភពលោកកម្ពុជា និងភាគីពាក់ព័ន្ធដទៃទៀតបានទទួលស្គាល់សមិទ្ធិផលរបស់គំរោង LEASECT នៅក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើហឹង្សាប្រឆាំងយែនឌ័រ អំពើធ្វើអាជីវកម្ម និងការរំលោភបំពាន។ ពួកគេក៏បានអះអាងអំពីតម្រូវការដើម្បីអោយ LEASETC ពង្រីកបន្ថែមក្រៅពីការកសាងសមត្ថភាពដល់មន្ត្រីអនុវត្តច្បាប់ គឺត្រូវឈានមុខគេនៅក្នុងការសម្របសម្រួលរាល់សកម្មភាពនានាទាក់ទងនឹងការការពារ និងក្រុមគោលដៅ។

ក្រោមការដឹកនាំរបស់ **ឯកឧត្តម ញ៉ូំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ** និងការទទួលយកអនុវត្តន៍ដោយ **ឧត្តមសេនីយ ម៉ិត គឹមហុង** និងដោយមានការគាំទ្រពីក្រសួងមហាផ្ទៃ និងការគាំទ្រជាឯកច្ឆ័ន្ទទៅលើគំរោង LEASETC ពីមន្ត្រីអនុវត្តច្បាប់ទាំងអស់ធ្វើឱ្យគេមានភាពជាម្ចាស់ការបានរឹងមាំលើគម្រោង LEASETC ។ ចំពោះបញ្ហានៃការជួញដូរកុមារ ការរំលោភផ្លូវភេទ ការធ្វើអាជីវកម្ម និងអំពើហឹង្សាក្នុងគ្រួសារ គឺត្រូវស្ថិតនៅក្នុង**វ៉ាដា**នៃការអនុវត្តច្បាប់ទាំងអស់- ការងារនេះទទួលបានការគាំទ្រប្រកបដោយការប្តេជ្ញាចិត្តខ្ពស់របស់ពួកគេក្នុងការស៊ើបអង្កេត និងបង្ក្រាបរាល់បទល្មើសទាំងនោះ និងមានសេចក្តីប៉ងប្រាថ្នាដ៏ខ្ពង់ខ្ពស់ក្នុងការបន្តអភិវឌ្ឍន៍ជាបន្តនូវសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនច្រើនថែមទៀត។

LEASETC បាននិងកំពុងបង្កើននីត្យានុគោលភាព ការគោរព និងសមត្ថភាពក្នុងការជម្រុញដល់ការធ្វើសេចក្តីសម្រេចចិត្តកំរិតខ្ពស់របស់រាជរដ្ឋាភិបាល និងកិច្ចប្រតិបត្តិការរបស់មន្ត្រីនគរបាលថ្នាក់ក្រោម។ ទីប្រឹក្សា

អន្តរជាតិបានចែករំលែកនូវចំណេះដឹង និងជំនាញប្រកបដោយប្រសិទ្ធិភាពដល់ក្រុមការងារ LEASETC ដែលបច្ចុប្បន្ននេះអាចអនុវត្តបាននូវភារកិច្ចសំខាន់ៗដោយម្ចាស់ការ ឬ ដោយមានការតាមដានត្រួតពិនិត្យតិចតួចប៉ុណ្ណោះ។ ការកែលម្អរទៅលើការធ្វើកោសលវិច្ឆ័យ និងប្រព័ន្ធប្រមូលភ័ស្តុតាងបានជួយដល់ការវាយតម្លៃនូវស្តង់ដានៃការអនុវត្តន៏ច្បាប់ជាក់ស្តែងរបស់កម្ពុជា។ មានការកោត សរសើរកាន់តែច្រើនឡើងអំពីកុមារដែលទទួលបានសិទ្ធិមនុស្ស "ស្មើគ្នា" ចំពោះកុមារដែលទំនាស់និងច្បាប់ ក៏ដូចជាការកើន ឡើងការទទួលស្គាល់នូវអន្តរទំនាក់ទំនងស្តីអំពីការការពារកុមាររបស់មន្ត្រីអនុវត្តច្បាប់ អ្នកបណ្តុះបណ្តាលនគរបាល និង មន្ត្រីក្រសួងមហាផ្ទៃ។

គម្រោង LEASETC មានភាពបត់បែន និងវិវត្តន៏ជាបន្តបន្ទាប់ដើម្បីឆ្លើយតបទៅនឹងបរិបទដែលកាន់តែទូលំទូលាយ ដូចជាការធ្វើកំណែទម្រង់ច្បាប់ ការអភិវឌ្ឍន៏គោលនយោបាយ និងតថភាពវប្បធមិសង្គម។ ក្រោយពីការអនុម័តិក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ស្តីពីអំពើហឹង្សាក្នុងគ្រួសាររួចមក LEASETC បានធ្វើបច្ចុប្បន្នភាពឯកសារបណ្តុះបណ្តាលនានា ទម្រង់មូលដ្ឋានទិន្នន័យ និងទម្រង់ធ្វើរបាយការណ៏នៃបណ្តាញទូរស័ព្ទទាន់ហេតុការណ៏ដើម្បីឱ្យស្របតាមច្បាប់ដែលទើប បានអនុម័តសំរាប់មូលដ្ឋានក្នុងការអនុវត្តជាក់ស្តែងតាមខ្លឹមសារជាធរមាន។

## II. **សាវតា**

## **ក្រសួងមហាផ្ទៃនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា**

រាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវការអភិវឌ្ឍន៏គួរអោយកត់សម្គាល់នៅក្នុងការកសាង និងស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធសង្គម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងហេដ្ឋារចនាសម្ព័ន្ធស្ថាប័នតាមរយៈការអនុវត្តន៏ ***ផែនការអភិវឌ្ឍន៏សេដ្ឋកិច្ច-សង្គមរយៈពេល៥ឆ្នាំលើកទី១ឆ្នាំ១៩៩៦-២០០០*** និងជោគជ័យនៃផែនការអភិវឌ្ឍន៏សេដ្ឋកិច្ច-សង្គមរយៈពេល៥ឆ្នាំលើកទី១។ ផែនការអភិវឌ្ឍន៏សេដ្ឋកិច្ច-សង្គមរយៈពេល៥ឆ្នាំលើកទី១ បានផ្តោតជាសំខាន់ទៅលើកំណើនម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍន៏សង្គម និងការលប់បំបាត់ភាពក្រីក្រ និង *"យុទ្ធសាស្ត្រត្រីកោណ"* ដែលផ្តោតលើៈ

១). ការកសាងសន្តិភាព ការស្តារស្ថិរភាព និងការថែរក្សាសន្តិសុខសម្រាប់ប្រទេសជាតិ និងប្រជាជន

២). ការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងការធ្វើប្រក្រតីកម្មនូវទំនាក់ទំនងជាមួយសហគមន៏អន្តរជាតិ និង

៣). ការលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។

"យុទ្ធសាស្ត្រចតុកោណ" នាពេលបច្ចុប្បន្នបានឆ្លុះបញ្ចាំងនៅក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិឆ្នាំ ២០១៣ សំដៅលើកកំពស់កំណើនសេដ្ឋកិច្ច បង្កើនការងារដល់ពលករកម្ពុជា ធានាឱ្យមានសមធម៌ និងយុត្តិធម៌សង្គម និងលើកកំពស់ប្រសិទ្ធភាពវិស័យសាធារណៈតាមរយៈការអនុវត្តន៍ផែនការសកម្មភាពអភិបាលកិច្ច និងការកែទម្រង់ស៊ីជម្រៅដែលមានភាពជាប់ទាក់ទង និងមានសង្គតភាពនូវលើគ្រប់វិស័យ និងគ្រប់កំរិត។

ដូចគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើកំណែទម្រង់សំខាន់ៗជាច្រើនដែលជួយកែលម្អរដល់អភិបាលកិច្ច គុណភាព ប្រសិទ្ធិភាព និងការផ្តល់សេវាសាធារណៈ។ នៅក្នុងវិស័យការពារជនងាយរងគ្រោះច្បាប់សំខាន់ៗដូចជា ក្រមនីតិវិធីរដ្ឋប្បវេណី (ឆ្នាំ២០០៦) ក្រមនីតិវិធីព្រហ្មទណ្ឌ (ឆ្នាំ២០០៧) ក្រមរដ្ឋប្បវេណី (ឆ្នាំ២០០៧) ច្បាប់ស្តីពីអំពើហឹង្សាក្នុងគ្រួសារ (ឆ្នាំ២០០៥) ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ឆ្នាំ២០០៨) ត្រូវបានអនុម័តរួច។[២]

តាមរយៈអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃបានសហការជាមួយក្រសួងយុត្តិធម៌នៅក្នុងការរៀបចំសេចក្តីព្រាងសារាចរ និងផែនការសកម្មភាពមួយដើម្បីទប់ស្កាត់ និងបង្ក្រាបសកម្មភាព "អនីតិជនប្រព្រឹត្តល្មើស"។ ក្រសួងមហាផ្ទៃបានរៀបចំផែនការយុទ្ធសាស្ត្រមួយស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរគ្រឿងញៀន អំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ និងអំពើធ្វើអាជីវលើកម្មពលកម្ម និងការពង្រឹងយន្តការគ្រប់គ្រងសម្រាប់ការអនុវត្តន៍ផែនការសកម្មភាពនេះនៅថ្នាក់កណ្តាល ថ្នាក់ខេត្ត-ក្រុង និងស្រុក ។

ការអភិវឌ្ឍន៍ដ៏ជាក់លាក់ជាច្រើនបានធ្វើឡើងផងដែរក្នុងការពង្រឹងក្របខ័ណ្ឌច្បាប់ដើម្បីការពារស្ត្រីតាមរយៈការដោះស្រាយសមភាពយែនឌ័រ និងសិទ្ធិស្ត្រីនៅក្នុងការរៀបចំ និងការអនុវត្តន៍ច្បាប់ក៏ដូចជាតាមរយៈការបង្កើនការយល់ដឹងជាសាធារណៈអំពីច្បាប់ដែលពាក់ព័ន្ធ។ ការអភិវឌ្ឍជាវិជ្ជមាននានាត្រូវបានកត់សម្គាល់ក្នុងចំណោមការអភិវឌ្ឍន៍ផ្សេងៗទៀតនៅក្នុងការបង្កើនចំនួនតំណាងជាស្ត្រីនៅក្នុងមុខតំណែងដឹកនាំរបស់រដ្ឋាភិបាល។ ឧទាហរណ៍ ចំនួនស្ត្រីដែលត្រូវបានជាប់ឆ្នោតនៅក្នុងរដ្ឋសភាបានកើនឡើងពី ៥% ក្នុងឆ្នាំ១៩៩៣ រហូតដល់ ២២% នៅក្នុងឆ្នាំ២០០៨ ហើយស្ត្រីដែលត្រូវបានជាប់ឆ្នោតនៅក្នុងក្រុមប្រឹក្សាឃុំ/សង្កាត់ក៏បានកើនឡើងពី ៨% ក្នុងឆ្នាំ ២០០៣ រហូតដល់ ១៤,៦% ក្នុងឆ្នាំ២០០៧។ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ បានចេញគោលការណ៍ណែនាំអំពីវិធានការដ៏វិជ្ជមានជាមួយនឹង**កូតា**ដែលមានចាប់ពី ២០% ដល់ ៥០% សម្រាប់ស្ត្រីក្នុងចំណោមបុគ្គលិកជ្រើសរើសថ្មីនៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈ។ ជាលទ្ធផល សមាមាត្រនៃមន្ត្រីរាជការជាស្ត្រីបានកើនឡើងពី

---

[២] **សូមមើលឧបសម្ព័ន្ធ ១ :** បញ្ជីនីតិកម្មដែលពាក់ព័ន្ធស្តីពីការការពារក្រុមងាយរងគ្រោះ និងជនរងគ្រោះ ដោយសារការរំលោភបំពាន អំពើហិង្សា និងការកេងប្រវ័ញ្ច

៣២% ក្នុងឆ្នាំ២០០៧ ដល់ ៣៨% នៅពាក់កណ្តាលឆ្នាំ២០០៩ ។

តែទោះជាយ៉ាងណាក៏នៅមានបញ្ហាប្រឈមនៅឡើយ ។ តុលាការមិនទាន់ទទួលបានទំនុកចិត្តពេញលេញពីសំណាក់សាធារណៈជននៅឡើយ ហើយក្របខ័ណ្ឌច្បាប់ទូលំទូលាយមួយមិនទាន់ត្រូវបានបង្កើតឡើងនៅឡើយ ។ ការអនុវត្តន៏ច្បាប់នៅតែជាបញ្ហាប្រឈមមួយដោយសារកត្តាផ្សេងៗ ដូចជា កង្វះសមត្ថភាព និងបៀវត្សរ៍ទាបរបស់មន្ត្រីអនុវត្តច្បាប់ ។ ការផលិត និងការជួញដូរគ្រឿងញៀនបានក្លាយជាបញ្ហាសង្គមមួយដែលកាន់តែកើនឡើង និងប៉ះពាល់ជាអវិជ្ជមាន ជាពិសេស ចំពោះយុវជនកម្ពុជា ។ ចំនួនស្ត្រីដែលមានឋានៈខ្ពស់/ថ្នាក់ធ្វើសេចក្តីសម្រេចចិត្តនៃមុខងារសាធារណៈនៅមានចំនួនតិចនៅឡើយ ហើយចំនួនស្ត្រីជាចៅក្រម និងជាព្រះរាជអាជ្ញានៅក្នុងតុលាការក៏មានចំនួនតិចដែរ ។ ឥរិយាបថ និងអាកប្បកិរិយាអវិជ្ជមាន និងរើសអើង អំពើហិង្សាប្រឆាំងយែនឌ័រ និងការធ្វើអាជីវកម្ម ព្រមទាំងការមាក់ងាយដល់ជនរងគ្រោះ ដោយសារអំពើហឹង្សាជាទូទៅនៅមានច្រើននៅឡើយ ។

ទោះបីជាមានការចុះថយយ៉ាងខ្លាំងនូវឧក្រិដ្ឋកម្មក៏ដោយ ឧបទ្ទវហេតុ ឬអំពើប្លន់ប្រដាប់អាវុធ ឃាតកម្ម ចរាចរណ៍ និងការជួញដូរគ្រឿញៀន ការរំលោភសេពសន្ថវៈ ការជួញដូរស្ត្រី និងកុមារ និងបទល្មើសផ្សេងដទៃទៀតមានដូចជាការរំលោភច្បាប់ដោយច្ចេកទេស និង ការលាងលុយកខ្វក់នៅតែមានចំនួនខ្ពស់នៅឡើយ ។ ការគ្រប់គ្រងរដ្ឋបាលមានភាពស្មុគស្មាញនៅក្នុងទីក្រុង និងទីប្រជុំជន និងមានអនីតិជនប្រព្រឹត្តិល្មើសនៅទីសាធារណៈ ។ រង្គសាល និងកន្លែងរាំកំពុងធ្វើអោយប៉ះពាល់ជាអវិជ្ជមានដល់យុវជន បង្កឱ្យមានភាពអសកម្មនៅក្នុងការសិក្សា មានការបោះបង់ចោលសាលារៀនដែលអាចនាំឱ្យឈានដល់ការប្រព្រឹត្តបទល្មើស ។

## នគរបាលជាតិកម្ពុជា

មានកម្លាំងនគរបាលដ៏រឹងមាំចំនួន៦៤.០០០នាក់ នៅក្នុងប្រាំមួយនាយកដ្ឋាន ដូចជានាយកដ្ឋានសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ដឹកជញ្ជូន នាយកដ្ឋានព្រំដែន នាយកដ្ឋានរដ្ឋបាល និងនាយកដ្ឋាននគរបាលយុត្តិធម៌ ។ នគរបាលជាតិកម្ពុជាដែលត្រូវបានឧបត្ថម្ភដោយគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា (CCJAP) បានបង្កើតផែនការយុទ្ធសាស្ត្រមួយសម្រាប់ឆ្នាំ២០០៨-២០១៣ ដោយមានទស្សនវិស័យថាៈ "**រួមគ្នាដើម្បីឱ្យ ប្រទេសកម្ពុជាមានសុវត្ថិភាពកាន់តែប្រសើរ**" - "Safer Cambodia Together" - និងបេសកកម្ម "**ធ្វើការរួមគ្នាដើម្បីបម្រើនិងការពារប្រជាជន —** Working Together to Serve and Protect the People" ។ នៅក្នុងគោលដៅយុទ្ធសាស្ត្រចំនួន១០របស់នគរបាលជាតិសម្រាប់ឆ្នាំ២០០៨-២០១៣ គឺ "**ការកាត់ បន្ថយអំពើធ្វើអាជីវកម្មលើស្ត្រី និងពលកម្មកុមារ ការជួញដូរផ្លូវភេទនៅក្នុងប្រទេសកម្ពុជា និងលើក**

**ស្តួយសេចក្តីថ្លៃថ្នូរ និងកិត្យានុភាពជាតិ" "ការការពារសន្តិសុខជាតិ និងការទប់ស្កាត់អំពើភេរវកម្មអន្តរជាតិ និងបណ្តាញឧក្រិដ្ឋកម្មឆ្លងដែន"** និងការលើកកំពស់នគរបាលជាតិកម្ពុជាឱ្យមានសមត្ថភាពវិជ្ជាជីវៈ និងមានសីលធម៌ល្អដែលប្រជាជនមានការជឿជាក់ និងគាំទ្រ" ។

## iii. បញ្ហាប្រឈម និងមេរៀនបទពិសោធន៍ដែលទទួលបាន

ការវាយតម្លៃរបស់ LEASETC បានបង្ហាញអំពីសមិទ្ធិផល និងមេរៀបបទពិសោធន៍ក្នុងការដោះស្រាយបញ្ហាការជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការរំលោភផ្លូវភេទ និងអំពើហឹង្សាក្នុងគ្រួសារដែលធ្វើឱ្យ ប៉ះពាល់ដល់កុមារ ។ ត្រូវមានៈ

១. តម្រូវការដើម្បីប្រែក្លាយ LEASETC អោយទៅជារចនាសម្ព័ន្ធផ្លូវការមួយនៅក្នុងក្រសួងមហាផ្ទៃ ដែលមានអាណត្តិច្បាប់លាស់ កំណត់អំពីល័ក្ខខ័ណ្ឌយោង និងយុទ្ធសាស្ត្រទូលំទូលាយរយៈពេលវែងមួយ ។ រាល់ការប្រឈមនានាក៏ត្រូវរួមបញ្ចូលទាំងផ្នែកសមត្ថភាព និងបទពិសោធន៍នៅមានកម្រិតក្នុងចំណោមមន្ត្រីក្រសួងមហាផ្ទៃ អំពីតួនាទីច្រើននៅក្នុងក្រសួង ខ្វះប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្លូវការ និងពេលវេលាមានកំរិត ធនធាន និងប្រព័ន្ធស្ថាប័ននៅមានកំរិត ។

២. អនុក្រឹត្យលេខ៤០ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០២ បានបង្កើតនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងអង្គភាពជំនាញនៅក្នុងខេត្តចំនួន១៧ ។ នាយកដ្ឋាននេះមានសមាសភាពជាមន្ត្រីរបស់ក្រសួងមហាផ្ទៃដែលត្រូវបានផ្ទេរមកពីអង្គភាពផ្សេងៗនៅក្នុងក្រសួង ជាពិសេសពីនាយកដ្ឋានអធិការកិច្ច នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នគរបាលជាតិកម្ពុជា អង្គភាពប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ទីបញ្ជាការដ្ឋាននគរ បាលខេត្ត និងរាជបណ្ឌិតសភានគរបាលកម្ពុជា ។

៣. សកម្មភាពបណ្តុះបណ្តាលទាន់ពេលវេលារបស់ LEASETC បានធ្វើអោយប្រសើរឡើងនូវសមត្ថភាពរបស់អង្គភាពប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន អង្គភាពអនុវត្តច្បាប់នៅមូលដ្ឋានដើម្បីដោះស្រាយបទល្មើសប្រឆាំងនឹងកុមារ ។ តែទោះជាយ៉ាងណាក៏ដោយ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពចាំបាច់ត្រូវធ្វើឱ្យទៅជាប្រព័ន្ធដើម្បីងាយស្រួលដល់ការកំនត់គោលដៅអ្នកចូលរួមឱ្យបានល្អប្រសើរ និងការគិតគូរអំពីតួនាទីរបស់ពួកគេ អំពីការទទួលខុសត្រូវ និងតម្រូវការការរៀនសូត្ររបស់ពួកគេ ។ មានតម្រូវការផ្នែកសម្របសម្រួល ការធ្វើសុខដុមកម្ម និងការធ្វើស្តង់ដា (បមាណីយកម្ម) បណ្តុះបណ្តាលនគរបាលនិងគំនិតផ្តួចផ្តើមកសាងសមត្ថភាពដែលពាក់ព័ន្ធ ផ្សេងៗ

ទៀត ជាពិសេសតម្រូវការរបស់ពួកគេធ្វើការងារទាក់ទងនឹងការការពារកុមារ និងក្រុមជនងាយរងគ្រោះដទៃទៀត។

៤. តម្រូវការដើម្បីពិនិត្យឡើងវិញអំពីអាណត្តិនៃបណ្តាញទូរស័ព្ទទាន់ហេតុការណ៍ និងតម្រូវការសមត្ថភាពប្រតិបត្តិការ និងរបៀបចំពិធីសារផ្ទៃក្នុងដើម្បីធានាថារាល់ការហៅទូរស័ព្ទបន្ទាន់ត្រូវបានឆ្លើយតបយ៉ាងសមស្រប និងភ្លាមៗ។ ប្រសិទ្ធភាព និងការហៅចូលខ្សែទូរស័ព្ទទាន់ហេតុការណ៍ត្រូវបានគ្រោងថានឹងទទួលបានការលើក កំពស់តាមរយៈកិច្ចសហការជាមួយអ្នកផ្តល់សេវាទូរគមនាគមន៍នៅក្នុងស្រុក។

៥. យន្តការរាយការណ៍អំពីមូលដ្ឋានទិន្នន័យមិនទាន់មានសុទិដ្ឋិនិយម និងប្រើប្រាស់ ឬពិនិត្យតាមដាន បានពេញលេញនៅឡើយ ហើយការប្រើប្រាស់មិនមានសង្គតភាពនឹងគ្នា។ ឧទាហរណ៍ មន្ត្រីមួយចំនួនបញ្ចូលទៅក្នុងទិន្ន័យតែករណី ឬ សំណុំរឿងដែលត្រូវបញ្ជូនទៅតុលាការតែប៉ុណ្ណោះ ចំណែកឯមន្ត្រីផ្សេងទៀតបញ្ចូលទៅក្នុងទិន្នន័យចំពោះករណីឃាត់ខ្លួនផងដែរ។

៦. មន្ត្រីអនុវត្តច្បាប់ ជាទូទៅខ្វះការយល់ដឹងច្បាស់លាស់ និងស៊ីជម្រៅ អំពីអ្វីជា "ដើមហេតុ" និងអ្វីដែលអាចទប់ស្កាត់បទល្មើសប្រឆាំងកុមារ ក៏ដូចជាកង្វះខាតការយល់ដឹងរវាងអំពើជួញដូរ និងអំពើធ្វើអាជីវកម្ម និងលើសនោះទៀតគឺការរំលោភលើការការពារកុមារ។ នោះគឺជាកត្តាទាំងឡាយដែលធ្វើឱ្យ កុមារងាយរងគ្រោះ ក្រីក្រ បែកបាក់គ្រួសារ ទទួលរងការរំលោភបំពាន។ល។ ដូច្នេះគួរត្រូវគិតពិចារ ណាអំពីវិធានការការពារ។

លើសពីនោះទៀត គឺមិនទាន់មានយុទ្ធសាស្ត្រសន្តនិយម (ទាំងមូល) ដែលលើកឡើងអំពីផ្នែកតម្រូវការ ដោយរួមបញ្ចូលអន្តរការី មានដូចជាភ្នាក់ងារជ្រើសរើសកម្លាំងពលកម្ម ភ្នាក់ងារផ្តល់ការទទួលស្គាល់ និងភ្នាក់ងារចេញអាជ្ញាប័ណ្ណជាដើម។ ដូច្នេះការទប់ស្កាត់ឧក្រិដ្ឋកម្មគប្បីធ្វើឡើងឱ្យហួសពីការផ្សព្វផ្សាយព័ត៌មាន។

៧. ការអនុវត្តន៍ការធ្វើកោសលវិច្ច័យគប្បីកែលម្អរដើម្បីធានានូវប្រសិទ្ធិភាពនិងប្រសិទ្ធិផលនៃមុខងាររបស់ប្រព័ន្ធ ដែលត្រូវបានដាក់អោយប្រើប្រាស់រួចហើយ និងដោយអនុលោមតាមពិធីសារស្តង់ដាទៀតផង។

៨. ចំពោះភ្នាក់ងារអនុវត្តច្បាប់ដែលបានបញ្ជូនរឿងក្តីទៅតុលាការមិនអាចបកស្រាយថាជាការកើនឡើងនូវភាគរយនៃករណីដែលត្រូវបានយកមកកាត់ទោសនោះទេ។ ភ័ស្តុតាងមិនគ្រប់គ្រាន់នឹងចង្អុលបង្ហាញអំពីភាពគ្មានសង្គតភាពរវាងតួលេខរបស់ការអនុវត្តច្បាប់ និងតួលេខរបស់តុលាការ។ នៅថ្នាក់តុលាការមានរបាយការណ៍អំពីរឿងក្តីដែលត្រូវបានលើកចោល ឬត្រូវបានបង្វែរឱ្យក្លាយជាបទល្មើសមួយដែលតូចជាង-ស្រាលជាង ហើយដោយមានហេតុផលផ្សេងៗ ក្នុងនោះមានទាំងការរៀបរាប់អំពីការប្រព្រឹត្តមិនត្រឹមត្រូវរបស់តុលាការទៀតផង។ ភាពខ្វះចន្លោះ/ភ័ស្តុតាងមិនគ្រប់គ្រាន់នៅក្នុងរឿងក្តីដែលបានបញ្ជូនទៅឱ្យតុលាការពីភ្នាក់ងារអនុវត្តច្បាប់ ឬភ័ស្តុតាងដាក់បន្ទុកមិនគ្រប់គ្រាន់ក្រោយពីមានការស៊ើបអង្កេតបន្ថែម ឬនៅពេលរឿងក្តីនោះមកចំពោះមុខតុលាការ។

៩. កម្រិតមិនស្មើគ្នានៃកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូរវាងអង្គភាពប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន អង្គភាពរដ្ឋាភិបាលដទៃទៀត និងអង្គការមិនមែនរដ្ឋាភិបាលគប្បីត្រូវបានដោះស្រាយ។ ធនធានរបស់ម្ចាស់ជំនួយ អង្គការជាតិ ឬអង្គការអន្តរជាតិត្រូវបែងចែកជាចំណែកៗទៅតាមបណ្តាក្រសួង (និងនាយកដ្ឋាននានារបស់ក្រសួង) ព្រមទាំងមានបែបបទ និង តម្រូវដោយឡែកៗពីគ្នាដែលរាំងស្ទះដល់ការសម្របសម្រួល និងកិច្ចសហការ។

១០. ក្រៅពីលទ្ធផលវិជ្ជមានរបស់ LEASETC ការវាយតម្លៃបានឆ្លុះបញ្ចាំងអំពីការគ្រប់គ្រង LEASETC របស់ក្រសួងមហាផ្ទៃដែលចាំបាច់ត្រូវធ្វើការពង្រឹងឡើងវិញ ជាពិសេសនៅក្នុងការធ្វើផែនការយុទ្ធសាស្ត្រ ការពិនិត្យតាមដាន និង ការវាយតម្លៃក៏ដូចជានៅក្នុងការបញ្ជ្រាប និងការសម្របសម្រួលជំនួយគាំទ្រដល់ការបណ្តុះបណ្តាលអនុវត្តច្បាប់ និង ប្រតិបត្តិការរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និង អង្គភាពប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្ត។

១១. ការដកជំនួយផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីសំណាក់ម្ចាស់ជំនួយនៅពេលនេះ គឺមិនស្រប ឡើយ។ ប៉ុន្តែ វាជាការសំខាន់ណាស់ដែលក្រសួងមហាផ្ទៃទទួលបាននូវថវិកាវិភាជន៍មួយចំនួន សម្រាប់គំរោង LEASETC នៅដំណាក់កាលបន្ទាប់។ ចំពោះគំរូ/ទម្រង់សំរាប់ចែករំលែកការចំណាយមួយអាចបង្កើតឡើងបាននៅពេលដែលក្រសួងមហាផ្ទៃអាចទទួលខុសត្រូវ និងមានគណនេយ្យភាពពេញលេញសម្រាប់គម្រោង។

## IV. ផ្លូវឆ្ពោះទៅមុខៈ ក្របខ័ណ្ឌយុទ្ធសាស្ត្រ ឆ្នាំ២០១១-២០១៥

គោលបំណងនៃក្រខ័ណ្ឌយុទ្ធសាស្ត្រគឺប្រែក្លាយ LEASETC ឱ្យក្លាយជាយន្តការនយោបាយ និងការសម្របសម្រួល និងជាយន្តការត្រួតពិនិត្យផ្លូវការមួយដើម្បីសម្របសម្រួលដល់អភិក្រមដែលគ្របដណ្តប់ដល់ការកសាងប្រព័ន្ធមួយគ្របដណ្តប់លើវិស័យទាំងមូល (**Sector-wide System-building Approach**) នោះគឺ "**ការលើកកំពស់ការអនុវត្តន៍ច្បាប់ស្តីពីការការពារកុមារនិងជនងាយរងគ្រោះ**" ឬជាភាសាអង់គ្លេសហៅថា "**Law Enforcement Advancing Protection of Children and Vulnerable Persons-** ឬហៅកាត់ថា **LEAP**) តាមរយៈដំណើរការនៃការពិគ្រោះយោបល់ជាមួយភ្នាក់ងាររដ្ឋាភិបាល និងដៃគូរអភិវឌ្ឍន៍សំខាន់ៗ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រគឺជាជំហ៊ានដំបូងដ៏សំខាន់នៅក្នុងដំណើការយុទ្ធសាស្ត្រទាំងមូលរបស់ **LEAP** ដែលបានស្ថាបនាឡើងតាមរយៈអនុសាសន៏ដ៏សមស្របពីការវាយតម្លៃទៅលើ **LEASETC** ឆ្នាំ២០០៩។ ក្រខណ្ឌ័នឹងបង្កើតនូវមូលដ្ឋានសំរាប់ការជ្រើសរើសនូវជំរើសយុទ្ធសាស្ត្រ និងអន្តរាគមន៍ដើម្បីដោះស្រាយរាល់រឿងរ៉ាវដែលបានរកឃើញតាមរយៈការសិក្សាវាយតម្លៃ និងរបាយការណ៏ត្រឡប់នឹងមតិយោបល់ដែលផ្តល់ដោយភាគីពាក់ព័ន្ធ និងភ្នាក់ងាររដ្ឋាភិបាល ដៃគូរអភិវឌ្ឍន៍ និងស្ថាប័នផ្តល់ហិរញ្ញប្បទាន ក៏ដូចជាមន្ត្រីអនុវត្តន៍ច្បាប់។ វាក៏បង្ហាញផងដែរអំពីសមាសធាតុនៃយុទ្ធសាស្ត្ររបស់ **LEAP** ដែលធានាដល់និរន្តរភាពនៃយន្តការ អំពីដំណើរការ និងអន្តរាគមន៏ដែលបានឯកភាពតាមរយៈការធ្វើសមាហរណកម្មទៅក្នុងមុខងាររបស់អាជ្ញាធរពាក់ព័ន្ធជាមួយក្រសួងមហាផ្ទៃ។

ការវាយតម្លៃ LEASETC ដំណាក់កាលទី៣ដែលធ្វើឡើងក្នុងឆ្នាំ២០០៩ បានបង្ហាញឱ្យឃើញ ថា មានសមិទ្ធផលធំៗជាច្រើនដែលសំរេចបាននៅក្នុងការលើកកំពស់សមត្ថភាពរបស់មន្ត្រីអនុវត្តន៍ច្បាប់ដើម្បីដោះស្រាយបទល្មើសប្រឆាំងនឹងកុមារ។ ជាពិសេស ការអនុវត្តន៏ច្បាប់នៅថ្នាក់ជាតិ និងនៅក្នុងខេត្តចំនួន១០ ដែលត្រូវបានទ៏ផ្តល់អំណាចដើម្បីឱ្យបានយល់ដឹងទូលំទូលាយអំពីបទល្មើសប្រព្រឹត្តិចំពោះកុមារ និងមនុស្សធំ និងអំពីធ្វើការសង្គ្រោះ ការស្តាប់ចម្លើយ និងការបញ្ជូនកុមារមេត្រីអនុវត្តការស៊ើបអង្កេតឱ្យបានកាន់តែប្រសើរ និងដើម្បីប្រមូលភ័ស្តុតាងឱ្យបានកាន់តែសុក្រិត សម្រាប់ការកសាងសំណុំរឿងដើម្បីយកមកកាត់ទោស។

កិច្ចអន្តរាគមន៍សម្រាប់ការអនុវត្តន៍ច្បាប់នៅតែស្ថិតនៅក្រោមការដឹកនាំរបស់ម្ចាស់ជំនួយ ហើយដែលជំនួយភាគច្រើនមានការគាំទ្រទោល (Stand-alone support) ដែលជាហេតុធ្វើឱ្យខ្វះនូវកិច្ចសហប្រតិបត្តិការ និង ខ្វះការបណ្តុះបណ្តាល ខ្វះទូរស័ព្ទទាន់ហេតុការណ៏ និងកម្មវិធីប្រមូលទិន្ន័យមិនគ្រប់គ្រាន់។ ការវាយតម្លៃបានលើកជាអនុសាសន៏ឱ្យ អនុម័តយកអភិក្រមដែលគ្របដណ្តប់ដល់ការកសាងប្រព័ន្ធមួយក្តោបលើវិស័យទាំងមូល (**Sector-wide System-building Approach**) សំរាប់ "**ការលើកកំពស់ការអនុវត្តន៏ច្បាប់ស្តីពីការការពារកុមារនិងជនងាយរងគ្រោះ**" ឬហៅកាត់ថា **LEAP**)។

អភិក្រមថ្មីនេះនឹងបញ្ចូលនូវកម្មវិធី LEASETC ដែលបានកែលម្អរួចដាក់បញ្ចូលទៅក្នុងរចនាសម្ព័ន្ធ និងប្រព័ន្ធផ្លូវការរបស់ក្រសួងមហាផ្ទៃ ដែលមានភាពជាអ្នកដឹកនាំដ៏រឹងមាំ មានភាពម្ចាស់ការ មានការត្រួតពិនិត្យ និងមានអាណត្តិដែលបំរើដូចជា "អ្នកយាមទ្វារ" ដើម្បីៈ ក). ធ្វើជាស្តង់ដា និងសម្របសម្រួលរាល់ការបណ្តុះបណ្តាលយុទ្ធសាស្ត្រសំរាប់មន្ត្រីនគរបាល ខ). ធ្វើសុខដមកម្មយន្តការ (ឧទាហរណ៏ៈ មូលដ្ឋានទិន្ន័យ បណ្តាញទូរស័ព្ទទាន់ហេតុការណ៏ ការធ្វើកោសលវិច្ច័យ ។ល។) ទាក់ទងនឹង ការបង្ក្រាបអំពើជួញដូរ អំពើធ្វើអាជីវកម្ម ការរំលោភសេពសន្ថវៈ និងអំពើហឹង្សាក្នុងគ្រួសារ ដែលអនុវត្តដោយនគរបាលជាតិកម្ពុជា នាយកដ្ឋាន ស្នងការនគរបាលខេត្ត-ក្រុង

និងនគរបាលមូលដ្ឋាន គ). ពង្រឹងសមត្ថភាពជាបន្តបន្ទាប់ដល់កម្លាំងនគរបាលជាតិដើម្បីពង្រឹងការអនុវត្តន៍ច្បាប់ គោលនយោបាយ និងនីតិវិធីឱ្យស្រប
តាមស្តង់ដាអន្តរជាតិ ។

អភិក្រមថ្មីនេះនឹងអនុញ្ញាតអោយមានការចូលរួមទូលំទូលាយពីគ្រប់កំរិតជាមួយសហគមន៍អភិវឌ្ឍន៍ ក្រៅពីម្ចាស់ជំនួយរបស់ LEASETC នាពេលបច្ចុប្បន្ន។ ការវាយតម្លៃនេះក៏បានស្នើឡើងផងដែរអំពីការផ្លាស់ប្តូរកម្មវិធី ជាក់លាក់ ដល់ក្រសួងមហាផ្ទៃ (ឧទាហរណ៍: ការបង្កើតអង្គភាពនគរបាលជំនាញនៅក្នុងនាយកដ្ឋាននគរបាលកណ្តាលយុត្តិធម៌ ដើម្បីគាំទ្រដល់ករណីកុមារទំនាស់នឹងច្បាប់ ការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការកសាងសមត្ថភាព ការបង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃ ។ល ។) ដែលចាំបាច់ត្រូវធ្វើសមាហរណកម្មទៅក្នុងយុទ្ធសាស្ត្រនេះ ។

ក្របខ័ណ្ឌយុទ្ធសាស្ត្រដែលត្រូវបានស្នើឡើងនេះកំណត់អំពីទិសដៅយុទ្ធសាស្ត្រ និងការតម្រង់ទិសពី LEASETC ទៅ LEAP ដែលត្រូវបង្កើតឡើងតាមរយៈការពិគ្រោះយោបល់មួយដែលមានការចូលរួមពីមន្ត្រីសំខាន់ៗរបស់ LEASETC MoI ក្រសួងមហាផ្ទៃ ដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ជំនួយជាដៃគូរ ។

# លំនាំនៃដំណើរការអនុវត្តន៍

| បច្ចុប្បន្ន<br>(គំរោង LEASETC នៅក្នុងឆ្នាំ២០១០) | ចំណុចខ្វះខាត/ភាពជាប់ទាក់ទង | អនាគត<br>(គំរោង LEAP នឹងចូលជាធរមានឆ្នាំ២០១១) |
|---|---|---|
| អ្នកផ្តល់ | តួនាទី | ការសម្របសម្រួល និងការតាមដានត្រួតពិនិត្យ |
| ខ្វះការសម្របសម្រួល | ការរៀបចំការបណ្តុះបណ្តាល | រៀបចំជាស្តង់ដា និងសុខដុមកម្ម |
| ប្រតិបត្តិការនៅក្នុងខេត្តចំនួន ៧ | សមត្ថភាពខាងខ្សែទូរស័ព្ទបន្ទាន់ | បានពង្រីក និងលើកកំពស់ |
| ច្បាប់ស្តីពីអំពើធ្វើអាជីកម្មផ្លូវភេទ ការជួញដូរ និង<br>អំពើហឹង្សាក្នុងគ្រួសារ<br>មូលដ្ឋានចំណេះដឹង វិក្រិតការ<br>និងមានការប.ប ជំនាញ | វិសាលភាព | អំពើហឹង្សាលើយែនឌ័រ ក្រមព្រហ្មទណ្ឌ និង<br>ក្រមនីតិវិធីព្រហ្មទណ្ឌ យុត្តិធមិអនីតិជន<br>មូលដ្ឋានចំណេះដឹង វិក្រឹតិការ<br>និង ជំនាញ |
| ការស្តាប់ចម្លើយកុមារមេត្រី — ការស៊ើបអង្កេត<br>ការស្រាវជ្រាវ - ការប្រមូលភ័ស្តុតាង | សមត្ថកិច្ច/សមត្ថភាព | លើកកំពស់ជំនាញក្នុងការអនុវត្តច្បាប់<br>( ការស៊ើបអង្កេត ការចាប់ខ្លួនជនល្មើស ការប្រមូល<br>ភ័ស្តុតាង និងការរៀបចំសំណុំរឿងទៅតុលាការ) |
| ប្រតិកម្ម | ការឆ្លើយតបទៅនឹងករណី | ប្រតិសកម្ម |
| អ្នកបណ្តុះបណ្តាល | ភាពជាដៃគូ/ការប្រកួតប្រជែង | សិក្ខាកាម |
| មើលផ្ទៃក្នុងមានលក្ខណៈរឹងមាំ | ស្មារតីនៃភាពជាម្ចាស់ការ | កែលម្អការយល់ឃើញពីខាងក្រៅទៅលើ<br>ភាពម្ចាស់ការរបស់ក្រសួងមហាផ្ទៃ |
| មិនមានទំនាក់ទំនងដោយផ្ទាល់ទៅ<br>នឹងរចនាសម្ព័ន្ធនគរបាល | រចនាសម្ព័ន្ធ | ធ្វើឱ្យស្របទៅនឹងរចនាសម្ព័ន្ធនគរបាលជាតិ |
| បុរសមានចំនួនលើសលប់ជាង | តុល្យភាពយេនឌ័រ | ការយល់ដឹងពីយែនឌ័រ |
| ការប្រមូលរាល់ទិន្នន័យទាក់ទងនឹងបទល្មើសៈ<br>រំលោភផ្លូវភេទ អំពើជួញដូរ និងអំពើហឹង្សា | ប្រព័ន្ធព័ត៌មាន | ការសេពប្រើគ្រឿងញៀន អំពើអាជីវកម្មតាម<br>រូបភាពសុំកូន លក់ពលកម្មដោះបំណុល<br>និងកុមារទំនាស់នឹងច្បាប់ |
| ប្រតិកម្ម | ការយល់ដឹងអំពីតួនាទី | ការបង្កា និងការទប់ស្កាត់ |
| ហិរញ្ញវត្ថុរដ្ឋមានកំរិត ភាគច្រើនជំនួយខាងក្រៅ | ប្រភពផ្តល់ហិរញ្ញប្បទាន | វិភាជន៍របស់រាជរដ្ឋាភិបាល |

LEASETC បាននិងកំពុងកសាងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ ជាពិសេស មន្ត្រីដែលធ្វើការនៅក្នុងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និង អង្គភាពនគរបាលខេត្តប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។ នគរបាលយុត្តិធមិនៅថ្នាក់ស្រុក និងថ្នាក់ឃុំក៏បានទទួលការបណ្តុះបណ្តាលតម្រង់ទិសទាក់ទងនឹងការជួញដូរ អំពើធ្វើអាជីវកម្ម

និងការរំលោភផ្លូវភេទ និងអំពើហឹង្សាក្នុងគ្រួសារ។ ការអនុវត្តន៍ច្បាប់នៅថ្នាក់ជាតិ និងនៅក្នុងខេត្តចំនួន១០ ដែលត្រូវបានផ្តល់អំណាចដើម្បីឱ្យបានយល់ដឹងទូលំទូលាយអំពីបទល្មើសប្រព្រឹត្តិចំពោះកុមារ និងមនុស្សធំ និងអំពីធ្វើការសង្គ្រោះ ការស្តាប់ចម្លើយ និងការបញ្ជូនកុមារមេត្រី អនុវត្តការស៊ើបអង្កេតឱ្យបានកាន់តែប្រសើរ និងដើម្បីប្រមូលភ័ស្តុតាងឱ្យបានកាន់តែសុក្រិតសម្រាប់ការកសាងសំណុំរឿង ដើម្បីយកមកកាត់ទោស។

LEAP គឺជាក្តីរំពឹងដល់ការលើកកំពស់សមត្ថភាពក្រសួងមហាផ្ទៃក្នុងការសម្របសម្រួល ការបណ្តុះបណ្តាល និងសកម្មភាពអភិវឌ្ឍន៍សមត្ថភាពផ្សេងៗជាច្រើនទៀតក្នុងចំណោមមន្ត្រីអនុវត្តន៍ច្បាប់ ក៏ដូចជាកាតាមដានត្រួតពិនិត្យ អំពីភាពជឿនលឿន និងលទ្ធផលពីសកម្មទាំងនេះក្នុងការការពារជនរងគ្រោះនៃអំពើជួញដូរ អំពើអាជីវកម្ម និងការរំលោភផ្លូវភេទ និងរាល់ទំរង់ផ្សេងៗទៀតនៃអំពើហឹង្សាលើយែនឌ័រ។

ក្រៅពី LEASETC មានអង្គការមួយចំនួនទៀតបាន និងកំពុងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីអ្នកអនុវត្តន៍ច្បាប់។ ដើម្បីទទួលឱ្យបានលទ្ធផលដ៏ប្រសើរបំផុត វាជាការសំខាន់ណាស់ដែលការការបណ្តុះបណ្តាលទាំងនេះបានធ្វើឱ្យមានសុខុដុមកម្ម និងស្តង់ដា។ នៅខណៈពេលដែលកម្មវិធីបណ្តុះបណ្តាលរបស់ LEASETC ត្រូវបានធ្វើសមាហរណកម្ម ទៅក្នុងរាជបណ្ឌិតសភាពនគរបាល និងសាលាបណ្តុះបណ្តាលនគរបាលប្រចាំភូមិភាគ រីឯការបណ្តុះ បណ្តាលផ្សេងៗទៀតមិនទាន់បានកត់ត្រាជាឯកសារនៅរបស់ក្រសួងមហាផ្ទៃនៅឡើយទេ ហើយគេក៏មិនដឹងថាតើមានសិក្ខាកាមប៉ុន្មាននាក់បានចូលរួមនៅក្នុងការបណ្តុះបណ្តាលទាំងនោះ។

LEAP នឹងដឹកនាំការធ្វើសុខុដុមរម្យនីយកម្ម និងស្តង់ដាសំរាប់ការបណ្តុះបណ្តាលនគរបាល។ ដៃគូអភិវឌ្ឍន៍នានាបានសម្តែងនូវការគាំទ្ររបស់ខ្លួនចំពោះដំណើរការនេះ។ គួរបង្កើតគណៈកម្មាធិការអាដហុកមួយដែលមានសមាសភាពមកពី LEAP រាជបណ្ឌិតសភានគរបាលកម្ពុជា និងអង្គការអភិវឌ្ឍន៍នានា។ ត្រូវប្រមូលផ្តុំកម្មវិធីសិក្សាទាំងអស់ ធ្វើការវាយតម្លៃ និងចាត់ទៅតាមប្រភេទសំរាប់កំរិតមូលដ្ឋាន សំរាប់ធ្វើវិក្រិតការ និងសំរាប់ជំនាញឯកទេស។ LEAP នឹងរក្សាកំណត់ត្រាអំពីចំនួនអ្នកដែលបានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល អំពីវគ្គបណ្តុះបណ្តាល ហើយនៅក្នុងកម្មវិធីអ្វីខ្លះ។ LEAP ក៏អាចដើរតួនាទីជាខ្លាំងស្តុករាល់ឯកសារទាំងអស់ដែលមានការពាក់ព័ន្ធ។ ហើយគួរបង្កើតឱ្យមានវេបសាយ៏ដើម្បីផ្សព្វផ្សាយ អំពីឯកសារបណ្តុះបណ្តាលទាំងនេះ។

ខ្សែទូរស័ព្ទទាន់ហេតុការណ៍បានដាក់អោយដំណើរការនៅរាជធានីភ្នំពេញ និងខេត្តចំនួន៦ផ្សេងទៀត។ ខ្សែទូរស័ព្ទទាន់ហេតុការណ៍ទាំងនេះនឹងត្រូវពង្រីក និងលើកកំពស់សំរាប់បំរើសាធារណជនអោយបានកាន់តែប្រសើរ។ យន្តការនានានឹងត្រូវបង្កើតឡើងដើម្បីលើកទឹកចិត្តដល់ជនរងគ្រោះ និងសាធារណជនឱ្យការរាយការណ៍អំពីបទល្មើសនានា។ ចំណាត់ការរបស់នគរបាលនឹងត្រូវលើកថែមទៀតដើម្បីឆ្លើយតបបានកាន់តែឆាប់រហ័សថែមទៀតទៅនឹងការរាយការណ៍តាមទូរស័ព្ទដែល បានរាយការណ៍តាមរយៈខ្សែទូរស័ព្ទទាន់ហេតុការណ៍។

វិសាលភាពការងាររបស់ LEASETC គឺទាក់ទងនឹងបញ្ហាជួញដូរមនុស្ស អំពើធ្វើអាជីវកម្ម និងការរំលោភផ្លូវភេទ និងអំពើហឹង្សាក្នុងគ្រួសារ។ LEAP នឹងពង្រីកការយកចិត្តទុកដាក់របស់ខ្លួនទៅលើគ្រប់ទម្រង់ទាំងអស់នៃអំពើហឹង្សាលើយែនឌ័រ និងពលកម្មដើម្បីដោះបំណុល ការសេពគ្រឿងញៀន ការស៊ុំកូនក្នុងបំណងធ្វើអាជីវកម្ម អំពើធ្វើអាជីវកម្មតាមរយៈអាពាហ៏ពិពាហ៏។ LEAP ក៏នឹងដោះស្រាយបញ្ហានានាដែលប្រឈមនឹងកុមារទំនាស់នឹងច្បាប់។

ការឆ្លើយតបរបស់នគរបាលទៅនឹងបទល្មើសនៃអំពើជួញដូរ អំពើធ្វើអាជីវកម្ម និងការរំលោភផ្លូវភេទ និងអំពើធ្វើអាជីវកម្មពលកម្ម និងអំពើហិង្សាក្នុងគ្រួសារ ដែលកន្លងមកមានប្រតិកម្មដោយសារនគរបាលតែងតែរង់ចាំរបាយការណ៍អំពីការរំលោភបំពានទាំងនេះមុនពេលពួកគេចាត់វិធានការឆ្លើយតប។ LEAP នឹងធានាផងដែរថា នគរបាលនឹងធ្វើការការងារទប់ស្កាត់នេះ ឧទាហរណ៍ៈ ដូចជាការធ្វើជាជនបង្គោលនៅតាមសាលារៀន និងសហគមន៍ក្នុងតួនាទី ការពារនិងទប់ស្កាត់អំពើធ្វើអាជីវកម្ម និងការរំលោភផ្លូវភេទ និង ចូលរួមយ៉ាងសកម្មនៅក្នុងការធ្វើអត្តសញ្ញាណកម្មជនរងគ្រោះដោយការបំពេញការងារនៅខាងក្រៅការិយាល័យរបស់ខ្លួន ហើយចាប់ផ្តើមកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើធ្វើអាជីវកម្ម និងការរំលោភផ្លូវភេទ។

មន្ត្រីនគរបាលភាគច្រើនដែលធ្វើការលើបញ្ហានៃការជួញដូរ អំពើធ្វើអាជីវកម្ម និងការរំលោភផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារគឺសុទ្ធតែបុរស។ LEAP នឹងធ្វើការជ្រើសរើស និងបណ្តុះបណ្តាលអ្នកអនុវត្តច្បាប់ដែលជាស្ត្រីបន្ថែមទៀតដូចមានបញ្ជាក់នៅក្នុងផែនការអភិវឌ្ឍយុទ្ធសាស្ត្រជាតិដើម្បីងាយស្រួលក្នុងការធ្វើសម្ភាសន៍ជាមួយជនរងគ្រោះដោយសារការជួញដូរ អំពើធ្វើអាជីវកម្ម និងការរំលោភផ្លូវភេទដែលជាសុទ្ធតែនារីភេទ។

LEASETC ត្រូវបានគេស្គាល់ពីខាងក្រៅថាជាគម្រោងមួយរបស់ UNICEF/អង្គការទស្សនៈពិភពលោក ទោះបីជាមានភាពម្ចាស់ការរឹងមាំជាពិសេសក្នុងចំណោមមន្ត្រីអនុវត្តច្បាប់ក៏ដោយ។ តែ LEAP នឹងធានាថា ភាពជាម្ចាស់ការលើ LEAP គឺក្រសួងមហាផ្ទៃ។

ប្រព័ន្ធប្រមូលទិន្នន័យមួយស្តីពីបទល្មើសផ្លូវភេទ អំពើជួញដូរ និងអំពើហឹង្សាក្នុងគ្រួសារត្រូវបានបង្កើតឡើងដែលមានការគាំទ្រពី LEASETC។ LEAP នឹងលើកស្ទួយប្រព័ន្ធមូលដ្ឋានទិន្នន័យនេះតាមរយៈការបន្ថែមចំនួនកុំព្យូទ័រ និងសម្ភារៈចាំបាច់ដទៃទៀត។ ទិន្នន័យអំពីរាល់ទម្រង់នៃអំពើហឹង្សាលើយេនឌ័រក៏នឹងត្រូវដាក់បញ្ចូលផងដែរ។ ហើយត្រូវបោះផ្សាយរបាយការណ៍ជាទៀងទាត់។ ការតាមដានត្រួតពិនិត្យ និងតាមឃ្លាំមើលជាទៀងទាត់លើករណីនានាដែលបានដាក់ជូនតុលាការនឹងត្រូវធ្វើឡើងដើម្បីធានាថា ជនរងគ្រោះត្រូវទទួលបានការការពារពីជនល្មើសដែលបានគេចខ្លួន ឬបានដោះលែង។

ក្រៅពីម៉ោងធ្វើការរបស់ក្រសួងមហាផ្ទៃ មន្ត្រីដែលបានចាត់តាំងឱ្យធ្វើការនៅក្នុងគម្រោង LEASETC បានទទួលប្រាក់ឧបត្ថម្ភពីអង្គការ UNICEF, WVC, IOM អង្គការសង្គ្រោះកុមារន័រវ៉េស Terres des Homes Netherlands, និង Kamonohashi ។ LEAP នឹងធ្វើការតស៊ូមតិជាមួយក្រសួងមហាផ្ទៃដើម្បីសុំថវិកាបន្ថែមទៀតដើម្បីគាំទ្រសកម្មភាពទាំងនេះ និងដើម្បីសម្រេចឱ្យបាននូវនិរន្តរភាពនេះ។

## ទស្សនៈវិស័យ

*"សង្គមមួយមានសន្តិភាព និងសមធម៌ជាទីដែលជនរងគ្រោះ និងក្រុមងាយរងគ្រោះទទួលបានការការពារគ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សាលើយេនឌ័រ ការធ្វើអាជីវកម្ម និងការរំលោភបំពាន ជាពិសេសអំពើជួញដូរ អំពើអាជីវកម្មផ្លូវភេទ និងអាជីវកម្មលើកម្លាំងពលកម្ម ការរំលោភផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារ ។"*

## បេសកកម្ម

*"ការលើកស្ទួយការអនុវត្តន៏ច្បាប់ឱ្យមានប្រសិទ្ធិភាព និងប្រសិទ្ធផលដោយសហការជាមួយវិស័យសុខុមាលភាពសង្គម វិស័យយុត្តិធម៌ និងសង្គមស៊ីវិលដើម្បីការពារជនរងគ្រោះ និងជនងាយរងគ្រោះពីអំពើហិង្សា និងការកេងប្រវ័ញ្ច"* ។

## អភិក្រម

អភិក្រម LEAP ស្តីពីការការពារគឺបង្កើតចេញពីអន្តរផ្នែកដែលពាក់ព័ន្ធគ្នាចំនួនបី ពោលគឺ **ប្រព័ន្ធសុខុមាលភាពសង្គមសម្រាប់កុមារ និងគ្រួសារ ប្រព័ន្ធយុត្តិធម៌ និងការធ្វើសមាហរណកម្មការផ្លាស់ប្តូរឥរិយាបថសង្គម**។ ប្រព័ន្ធនេះបង្កើតឡើងសំដៅទប់ស្កាត់រាល់អំពើហិង្សាមិនឱ្យកើតមានឡើង និងផ្តល់ការការពារដល់កុមារ និងជនងាយរងគ្រោះនៅគ្រប់ស្ថានភាពទាំងអស់ និងគ្រប់ទំរង់នៃអំពើហិង្សា ឬកាលៈទេសៈដែលអំពើហិង្សានេះកើតឡើង គិតទាំងក្នុងស្ថានភាពអាសន្ន ជម្លោះ និងក្នុងរយៈពេលអន្តរកាល។ ប្រព័ន្ធនេះក៏នឹងលើកស្ទួយដល់ឥរិយាបថ ជំនឿ គុណតម្លៃ និងអាកប្បកិរិយាដែលធានាដល់សុខុមាលភាព និងការការពារជនងាយរងគ្រោះ ដូចជាការអះអាងអំពីសិទ្ធិមនុស្សរបស់កុមារដូចមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ពិធីសារជម្រើសនៃអនុសញ្ញានេះ និងលិខិតុបករណ៍អន្តរជាតិដទៃទៀត ។

LEAP ប្តេជ្ញាក្នុងការផ្តល់កម្មវិធីដើម្បីជួយដល់ការពង្រឹងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពក្រសួងមហាផ្ទៃដើម្បីទប់ស្កាត់រាល់អំពើហិង្សាលើយេនឌ័រ អំពើធ្វើអាជីវកម្ម និងការរំលោភបំពានទៅលើកុមារ ស្ត្រី និងបុរស ការពារ និង ជួយជនរងគ្រោះអំពើល្មើសទាំងនេះ ចាប់ខ្លួនជនល្មើសបញ្ជូនទៅតុលាការ។

## គោលការណ៍ណែនាំ

ក្របខ័ណ្ឌយុទ្ធសាស្ត្រ LEAP ឆ្នាំ២០១១-២០១៥ គឺផ្អែកលើគោលការណ៍ណែនាំដូចខាងក្រោម :

- ភាពម្ចាស់លការរបស់រាជរដ្ឋាភិបាល
- ការប្រព្រឹត្តចំពោះជនរងគ្រោះដោយផ្អែកលើសិទ្ធិមនុស្ស
- ការរៀបចំកម្មវិធីដោយផ្អែកលើយេនឌ័រ
- អភិក្រមសំរាប់ទូទាំងវិស័យ
- ការចូលរួមរបស់សង្គមស៊ីវិល
- ការសម្របសម្រួលអន្តរពហុវិស័យ និងការឆ្លើយតបរួម ទាំងក៏រិតរដ្ឋាភិបាល និងរវាងរដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាលជាតិ និង អន្តរជាតិ។
- ការពិនិត្យតាមដាន និងវាយតម្លៃជាប្រព័ន្ធ និងនិរន្តរភាព

**ភាពម្ចាស់លការរបស់រាជរដ្ឋាភិបាល**

LEAP គឺជាអង្គភាពផ្លូវការមួយរៀបចំឡើងក្រោមក្រសួងមហាផ្ទៃ ហើយរាជរដ្ឋាភិបាលទទួលខុសត្រូវទាំងស្រុង ក្នុងការងារគ្រប់ ប្រតិបត្តិការ និងការគៀងគរហិរញ្ញប្បទាន។

**ការប្រព្រឹត្តចំពោះជនរងគ្រោះដោយផ្អែកលើសិទ្ធិមនុស្ស**

សិទ្ធិ និងសុខុមាលភាពរបស់ជនរងគ្រោះ និងក្រុមគោលដៅងាយរងគ្រោះត្រូវចាត់ទុកជាសារៈសំខាន់ដ៏មាន ឧត្តមភាពបំផុត ដូចមានចែង នៅក្នុងគោលនយោបាយ និងការអនុវត្តន៍ជាក់ស្តែងរបស់ LEAP។ LEAP ធានាថារាល់ប្រព្រឹត្តិកម្មទៅលើក្រុមជនទាំងនេះគឺពិតជាប្រកបដោយការគោរព និងអនុឡោមតាមលិខិតុបករណ៍ និង ពិធីសារអន្តរជាតិ។ ដោយលិខិតុបករណ៍ទាំងនោះមានចែងអំពីការថែទាំ និងការប្រុងប្រយ័ត្នជាអាទិភាពចំពោះការសម្ងាត់នៃព័ត៌មានផ្ទាល់ខ្លួន និងការចៀសវាងការរងគ្រោះជាថ្មី។ ត្រូវផ្តល់ធនធានគ្រប់គ្រាន់ដើម្បីជួយសំរួលកុំឱ្យមានសម្ពាធទៅលើជនរងគ្រោះ ដោយសារការទាមទារថ្លៃសេវាកម្ម (ការធ្វើកោសលវិច្ឆ័យ ការផ្តល់ការព្យាបាលជាដើម ។ល។)។

**ការរៀបចំកម្មវិធីដោយផ្អែកលើមូលដ្ឋានយែនឌ័រ**

គោលនយោបាយ កម្មវិធី និងសកម្មភាពនានាដែលរៀបចំឡើងត្រូវគិតគូរអំពីលក្ខណៈពិសេសនៃក្រុមគោលដៅជាយែនឌ័រ។ LEAP មើលឃើញថាបញ្ហានៃអំពើហឹង្សាលើយែនឌ័រ និងការរំលោភសិទ្ធិមនុស្សមានការកើនឡើងចំពោះសហគមន៍ និងសង្គមដែលត្រូវយកចិត្តទុកដាក់។ នេះមានន័យថា ការប្រើប្រាស់ទិន្ន័យមិនមែនត្រឹមតែបង្ហាញដល់អ្នកធ្វើគោលនយោបាយអំពីទំហំផលប៉ះពាល់ពីអំពើហឹង្សាលើយែនឌ័រប៉ុណ្ណោះទេ ប៉ុន្តែវាក៏បញ្ជាក់ផងដែរអំពីសិទ្ធិជាសកលរបស់ស្ត្រីដើម្បីរស់នៅដោយគ្មានអំពើហឹង្សានៅគ្រប់កាលៈទេសៈ។ **"វប្បធម៌ និង ប្រពៃណី"** មិនអាចធ្វើជាហេតុផលដើម្បីប្រើ (ធ្វើយុត្តិកម្ម) អំពើហឹង្សាប្រឆាំងនឹងស្ត្រីបានឡើយ ហើយសហគមន៍ត្រូវតែធ្វើការទាមទារឱ្យផ្លាស់ប្តូរទស្សនៈដែលព្រមទទួលយកអំពើហឹង្សា និងថាជារឿងផ្ទាល់ខ្លួន។

**អភិក្រមក្រមសមាហរណកម្មទូទាំងវិស័យ**

LEAP លើកទឹកចិត្តឱ្យមានការសម្របសម្រួលជាមួយដៃគូរនៅគ្រប់កំរិត។ ឡាំភ នឹងសម្របសម្រួល បង្កើតភាពជាដៃគូរជាមួយភាគីពាក់ព័ន្ធទាំងអស់រួមទាំងស្ថាប័នបណ្ឌិតសភា/ស្ថាប័នស្រាវជ្រាវ ក្រុមអ្នកតស៊ូមតិ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន និងម្ចាស់ជំនួយទ្វេភាគី និង ពហុភាគី និងស្ថាប័នជាតិ តំបន់ និងអន្តរជាតិដើម្បីធ្វើការសម្របសម្រួលឱ្យប្រកបដោយឧត្តមភាពតាមអភិក្រមរួមគ្របដណ្តប់លើគ្រប់វិស័យ។

LEAP នឹងចូលរួមក្នុងការអភិវឌ្ឍន៏នូវប្រព័ន្ធការពាជាតិមួយប្រកបដោយប្រសិទ្ធិភាពដើម្បីពង្រឹងការការពារជនរងគ្រោះពីអំពើធ្វើអាជីវកម្ម និងការរំលោភបំពានផ្លូវភេទ និងជនងាយរងគ្រោះ។ ប្រព័ន្ធនឹងការពារមិនឱ្យកើតមានការរំលោភបំពាន និងការពារជនរងគ្រោះ និងជនងាយរងគ្រោះនៅគ្រប់ស្ថានភាពទាំងអស់ រួមទាំងគ្រោះអាសន្ន ការជម្លោះ និងរយៈពេលអន្តរកាល។

**ការចូលរួមរបស់សង្គមស៊ីវិល**

LEAP ទទួលស្គាល់ផលប៉ះពាល់ដែលសង្គមស៊ីវិលអាចជួបប្រទះទាក់ទងនឹងការកែលំអរការការពារ និងសេវាអនុវត្តន៏ច្បាប់ចំពោះជនរងគ្រោះពីអំពើធ្វើអាជីវកម្ម និងការរំលោភបំពាន។ សង្គមស៊ីវិលអាចដើរតួនាទីជាដៃគូរក្នុងការកសាងសមត្ថភាពមន្ត្រីអនុវត្តន៏ច្បាប់ និងផ្តល់សេវាកម្មខាងស្មានីតិសម្បទាដល់ជនរងគ្រោះនៃអំពើហឹង្សាលើយែនឌ័រ។ ហេតុដូច្នេះហើយ អ្នកទទួលសេវាកម្មត្រូវពិគ្រោះយោបល់ឱ្យបានទៀងទាត់ដើម្បីប្រាប់ និងដឹកនាំសកម្មភាព LEAP ដើម្បីជា ឧត្តមប្រយោជន៏សំរាប់ជនរងគ្រោះពីអំពើធ្វើអាជីវកម្ម និងការរំលោភផ្លូវភេទ។

**ការសម្របសម្រួលអន្តរពហុវិស័យ និងការឆ្លើយតបរួម ទាំងក៏រិតរដ្ឋាភិបាលនិងរវាងរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ**

LEAP នឹងគាំទ្រកិច្ចអន្តរាគមន៏ពហុវិស័យដើម្បីលើកកំពស់ប្រសិទ្ធិភាពដល់សកម្មភាពការពារ និងទប់ស្កាត់ទាំងនោះ។ ភាពជាដៃគូររវាងក្រសួងមហាផ្ទៃតាមរយ: LEAP និងអង្គការមិនមែនរដ្ឋាភិដែលបាលចូលរួមអនុវត្តន៏សកម្មភាព LEAP នឹងត្រូវបង្កើតឡើងជាផ្លូវការ និងរក្សាឱ្យមាននិរន្តរភាព។ រាល់តួនាទីភាពជាដៃគូររួមមានទាំងការចែករំលែកព័តិមាន ការពិគ្រោះយោបល់ ការចូលរួមក្នុងការអនុវត្តន៏គំរោង និងការវាយតម្លៃគំរោង។

**ការពិនិត្យតាមដាន និងវាយតម្លៃជាប្រព័ន្ធ និងនិរន្តរភាព**

ការពិនិត្យតាមដាន និងការវាយតម្លៃគឺជាផ្នែកមួយដ៏សំខាន់ចាំបាច់នៃកម្មវិធី LEAP។ ការពិនិត្យតាមដាន និងការវាយតម្លៃរឹងមាំជួយដល់ការកំណត់សំគាល់អំពីការអនុវត្តន៏ល្អប្រសើរដែលអាចលើកកំពស់ដល់ការបង្ការ និងការទប់ស្កាត់ និងកម្មវិធីសំរាប់ការឆ្លើយតបនាពេលអនាគត។

**គោលដៅរួម**

គោលដៅដ៏ចម្បងរបស់ LEAP គឺការពង្រឹងសមត្ថភាព និងប្រសិទ្ធិភាពនៃវិស័យអនុវត្តច្បាប់នៅក្នុងការទប់ស្កាត់ និងការចាប់ជនល្មើសទៅតុលាការ និងការសម្របសម្រួលសកម្មភាពទប់ស្កាត់ទាក់ទងនឹងអំពើធ្វើអាជីវកម្ម និងអំពើហឹង្សាទៅលើជនងាយរងគ្រោះ ជាពិសេសកុមារ និងស្ត្រី និងការការពារជនរងគ្រោះពីអំពើធ្វើអាជីវកម្ម និងការរំលោភបំពាន ។

គោលដៅ និងគោលបំណងជាយុទ្ធសាស្ត្ររបស់ LEAP ផ្តោតលើផ្នែកបីសំខាន់ៈគឺ : ការបង្ការ ការការពារ និងការសម្របសម្រួល។

ក្របខ័ណ្ឌយុទ្ធសាស្រ្ត LEAP នឹងដោះស្រាយបញ្ហានានាដែលទាក់ទងនឹងអំពើធ្វើអាជីវកម្មផ្លូវភេទ និង អាជីវកម្មលើពលកម្ម អំពើជួញដូរមនុស្ស អំពើហឹង្សាក្នុងគ្រួសារ ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ ការសេព គ្រឿងញៀន អំពើធ្វើអាជីវកម្មតាមរយៈការសុំកូនចិញ្ចឹម អំពើធ្វើអាជីវកម្មតាមរយៈអាពាហ៍ពិពាហ៍ យុត្តិធម៌ អនីតិជន និងកុមារទំនាស់នឹងច្បាប់ ។

## គោលដៅយុទ្ធសាស្ត្រទី ១

### ទប់ស្កាត់រាល់ទម្រង់ទាំងអស់នៃអំពើហឹង្សាប្រឆាំងកុមារ និងក្រុមងាយរងគ្រោះដទៃទៀត

**យុទ្ធសាស្ត្រ :**

១. LEAP តាមរយៈគំរោងប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន (AHTJP) (នឹងត្រូវដាក់ឈ្មោះថ្មី) នឹងចូលរួមយ៉ាងសកម្មនៅក្នុងការរៀបចំតាក់តែងច្បាប់ គោលនយោបាយ និង គោលការណ៍ណែនាំស្ដីអំពីអំពើហឹង្សា និងអំពើធ្វើអាជីវកម្ម និងការរំលោភផ្លូវភេទ ។

២. LEAP នឹងផ្សព្វផ្សាយ (ដោយសម្របសម្រួលជាមួយក្រសួងយុត្តិធម៌ ក្រសួងទេសចរណ៍ ក្រសួងសង្គមកិច្ច អតីតៈយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសុខាភិបាល និងស្ថាប័នពាក់ព័ន្ធដទៃទៀត) ច្បាប់ គោលនយោបាយ និងគោលការណ៍ណែនាំក្នុងចំណោមនគរបាលជាតិកម្ពុជា ទាំងនៅថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក និងឃុំ ។

៣. LEAP នឹងសហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតដើម្បីរៀបចំការបណ្ដុះបណ្ដាលសំរាប់មន្ត្រីនគរបាលយុត្តិធម៌ និងអាជ្ញាធរមូលដ្ឋានអំពីច្បាប់ និងគោលនយោបាយទាក់ទងនឹងអំពើជួញដូរ អំពើហិង្សាក្នុងគ្រួសារ អំពើធ្វើអាជីវកម្មផ្លូវភេទ និងអាជីវកម្មពលកម្ម និងការរំលោភផ្លូវភេទ និង តួនាទីនៃការអនុវត្តន៍ច្បាប់ក្នុងការស៊ើបអង្កេតរាល់បទល្មើសទាំងនេះ ។

៤. LEAP នឹងចូលរួមនៅក្នុងយុទ្ធនាការទប់ស្កាត់ផ្សេងៗ ដែលធ្វើឡើងដោយស្ថាប័ននានា ។

៥. LEAP នឹងរៀបចំសកម្មភាពបង្កា ទប់ស្កាត់ និងសុវត្ថិភាពសហគមន៍ទាក់ទងនឹងអំពើហឹង្សាលើយែនឌ័រ អំពើធ្វើអាជីវម្ម និងការរំលោភបំពាន ។ ឧទាហរណ៍ ធ្វើជាជនបង្គោលនៅក្នុងសាលារៀន និងសហគមន៍ ស្តីអំពីបញ្ហាសន្តិសុខ ។

៦. LEAP នឹងសម្របសម្រួលជាមួយនឹងស្ថាប័នផ្សេងៗទៀតក្នុងការរៀបចំ និងអនុវត្តន៏ការបណ្តុះបណ្តាលអំពីអាកប្បកិរិយាការពារកុមារ និងក្រុមជនងាយរងគ្រោះ ។

**គោលដៅយុទ្ធសាស្ត្រទី ២**

**ការពារជនរងគ្រោះដោយសារអំពើហិង្សាប្រឆាំងយេនឌ័រ អំពើធ្វើអាជីវកម្ម និងការរំលោភបំពាន និងនាំជនប្រព្រឹត្តល្មើសទៅកាន់តុលាការ**

**យុទ្ធសាស្ត្រ:**

១. LEAP នឹងរៀបចំប្រព័ន្ធដ៏សកម្មមួយសំរាប់ធ្វើអត្តសញ្ញាណកម្មជនរងគ្រោះ (ជំនួសឱ្យការរង់ចាំជនរងគ្រោះ ឬជនដទៃរាយការណ៍អំពីបទល្មើសនោះឡើយ) ។

២. មន្ត្រីអនុវត្តច្បាប់ត្រូវអនុវត្តប្រតិបត្តិការសង្គ្រោះប្រកបដោយប្រសិទ្ធិភាព និងប្រសិទ្ធិផល និង ធានារក្សាការសម្ងាត់នៃព័តិមានដែលផ្តល់ដោយជនរងគ្រោះ ។ល។

៣. មន្ត្រីអនុវត្តច្បាប់ត្រូវចាប់ខ្លួនជនល្មើស និងចារី និងត្រូវមានឯកសារជាចាំបាច់ (ឧទាហរណ៍ ដីកាចាប់ខ្លួន)

៤. LEAP នឹងលើកកំពស់ដល់ប្រព័ន្ធបញ្ជូនជនរងគ្រោះទៅកាន់សេវាកម្មសុខភាព និងផ្នែកចិត្តសាស្ត្រ ។

៥. មន្ត្រីអនុវត្តច្បាប់ត្រូវប្រមូលភ័ស្តុតាងដោយហ្មត់ចត់ និងប្រុងប្រយ័ត្ន ដើម្បីដាក់បន្ទុកលើជនល្មើសពេលយកមកកាត់ទោស ។

៦. LEAP នឹងធានាឱ្យមានប្រព័ន្ធកត់ត្រាឯកសារប្រកបដោយប្រសិទ្ធភាព (មូលដ្ឋានទិន្នន័យ) ធ្វើការតាមដានត្រួតពិនិត្យឱ្យបានទៀងទាត់ និងតាមដានករណីដែលបានស៊ើបអង្កេត និងចាត់វិធានការជាបន្ទាន់ដើម្បីការពារជនរងគ្រោះដែលជនល្មើសកំពុងគេចខ្លួន ឬត្រូវបានដោះលែងពីពន្ធនាគារ ។

៧. LEAP នឹងធានាដល់ការពង្រឹងវិធានការដើម្បីធានាអំពីការសម្ងាត់នៃព័តិមាន ។

៨. LEAP នឹងធានាថា ការស្តាប់ចម្លើយកុមារមេត្រីនឹងធ្វើឡើងដោយមន្ត្រីនគរបាលជាស្ត្រី និងដោយមានវត្តមានរបស់ឪពុកម្តាយ ឬអាណាព្យាបាលកុមារ ដោយប្រកាន់ខ្ជាប់គោលការណ៍យេនឌ័រ ។

## គោលដៅយុទ្ធសាស្ត្រទី ៣

## ពង្រឹងសមត្ថភាពស្ថាប័នក្រសួងមហាផ្ទៃដើម្បីគ្រប់គ្រងសកម្មភាព រៀបចំយន្តការសម្របសម្រួលសមស្រប ដែលគាំទ្រការអនុវត្តន៍សកម្មភាពកម្មវិធី

**យុទ្ធសាស្ត្រ:**

- LEAP នឹងរៀបចំផែនការសកម្មភាពរយៈពេល៥ឆ្នាំដែលគូសបញ្ជាក់អំពីយុទ្ធសាស្ត្រអន្តរាគមន៍សំរាប់ការអនុវត្តន៍ច្បាប់ដើម្បីផ្តល់សេវាការពារឱ្យបានកាន់តែប្រសើរដល់ជនរងគ្រោះនៃអំពើអាជីវកម្ម និងការរំលោភផ្លូវភេទ អំពើជួញដូរមនុស្ស អំពើអាជីវកម្មតាមរយៈការសូមកូនចិញ្ចឹម អំពើអាជីវកម្មតាមរយៈអាពាហ៍ពិពាហ៍ និងអំពើហឹង្សាប្រឆាំងយេនឌ័រ ការសេពគ្រឿងញៀន និងកុមារទំនាស់នឹងច្បាប់ ។

- LEAP នឹងបង្កើតយន្តការសហការ និងកិច្ចសហប្រតិបត្តិការ ដោយផ្សារភ្ជាប់ជាមួយស្ថាប័នពាក់ព័ន្ធនានា និងក្រុមសង្គមស៊ីវិល (ជាពិសេសជាមួយក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច អតីតៈយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល និងក្រសួងទេសចរណ៍ ក៏ដូចជាស្ថាប័នអន្តរក្រសួង មានដូចជា គណៈកម្មាធិការជាតិ ក្រុមការងារខេត្តប្រឆាំងការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រុមប្រឹក្សាជាតិដើម្បីកុមារកម្ពុជា និង COMMIT (TIPSE, CNCC and COMMIT) ដើម្បីកែលំអរប្រសិទ្ធិភាពនៃការផ្តួចផ្តើមការអនុវត្តន៍ច្បាប់ និងជួយ បង្កា និងទប់ស្កាត់រាល់ទំរង់នៃអំពើហឹង្សាប្រឆាំងយេនឌ័រ និងការការពារជនរងគ្រោះ និងគ្រួសារ របស់ពួកគេ) ។

- LEAP នឹងធ្វើសុខដុមកម្ម និងស្តង់ដាសកម្មភាពបណ្តុះបណ្តាលសំរាប់មន្ត្រីអនុវត្តន៍ច្បាប់ និងអាជ្ញាធរមូលដ្ឋាន។ LEAP នឹង***បង្កើតគណៈកម្មការពិនិត្យ និងរៀបចំការបណ្តុះបណ្តាលនគរបាល*** (Ad-hoc Police Training Steering Committee) ដើម្បីជួយដល់ការប្រមូល ការធ្វើសម្ភាសន៍ ការធ្វើចំណាត់ថ្នាក់ ការរៀបចំឯកសារ និងការវាយតម្លៃរាល់ឯកសារបណ្តុះបណ្តាលស្តីពីការពង្រឹងការអនុវត្តន៍ច្បាប់ ។

- LEAP នឹងពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងលើកកំពស់ការគ្រប់គ្រងកម្មវិធី និងជំនាញបច្ចេកទេសដល់ក្រុម LEAP និង មន្ត្រីនគរបាលនៃនាយកដ្ឋានពាក់ព័ន្ធដែលធ្វើការក្រោមគំរោង LEAP ។

- LEAP នឹងរៀបចំយុទ្ធសាស្ត្រដែលបង្កើនដល់ការងារជាក់ស្តែងនៃកម្មវិធី ។

- LEAP នឹងពង្រឹងទិន្ន័យការគ្រប់គ្រងករណីនៅក្នុខេត្តទាំងប្រាំពីរ ( ៧) ។
- LEAP នឹងរៀបចំ ហើយអនុវត្តប្រព័ន្ធតាមដាន និងវាយតម្លៃដែលអនុម័តរួចដើម្បីគាំទ្រដល់ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការយុទ្ធសាស្ត្រ។ LEAP នឹងសម្របសម្រួលដល់ការវាយតម្លៃការអនុវត្តន៏ការងារប្រចាំ និង មន្ត្រី LEAP ។

- LEAP នឹងសម្របសម្រួលដល់ការបង្កើតអង្គភាព ឬការិយាល័យជំនាញ " កុមារទំនាស់នឹងច្បាប់ " នៅក្នុងនាយកដ្ឋានមួយដែលស្ថិតនៅក្រោមអគ្គស្នងការនគរបាលជាតិ ឬនៅក្នុងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ។

## V. រចនាសម្ព័ន្ធចាត់តាំង និងភាពជាដៃគូ

LEAP នឹងបន្តស្ថិតនៅក្រោមការដឹកនាំរបស់ **ឯកឧត្តម ញ៉ូវ សុខា** ។ គួរមានអនុក្រិត្យមួយ ដើម្បីសមាហរណកម្ម LEAP ជាផ្លូវការនៅក្នុងអគ្គស្នងការដ្ឋាននគរបាលជាតិ។ រីឯបណ្តាញទំនាក់ទំនងផ្លូវការត្រូវកំណត់មន្ត្រី LEAP (ទីប្រឹក្សាអន្តរជាតិ ប្រធានគម្រោង អ្នកសម្របសម្រួលគម្រោង) និងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន (ដែលនឹងត្រូវដាក់ឈ្មោះថ្មីដើម្បីឆ្លុះបញ្ចាំងអំពីការវិវត្តន៏ផ្លាស់ប្តូរនៅក្នុងអាទិភាពគោលដៅ និងរចនាសម្ព័ន្ធ)។ មន្ត្រីអនុវត្តច្បាប់នៅក្នុងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនត្រូវតែងតាំងជាផ្លូវការទៅកាន់នាយដ្ឋាននេះ និងស្ថិតនៅក្រោមការគ្រប់គ្រងជាផ្លូវការរបស់នាយកដ្ឋានដែលមាន **ឯកឧត្តម ប៊ិត គឹមហុង** ជាប្រធាន។

### រចនាសម្ព័ន្ធបច្ចុប្បន្នរបស់ LEASETC ឆ្នាំ២០០០-២០១០



# រចនាសម្ព័ន្ធរបស់ LEAP ដែលបានស្នើឡើងសម្រាប់ឆ្នាំ២០១១-២០១៥



# VI. ក្របខ័ណ្ឌយុទ្ធសាស្ត្រទូទៅរបស់ LEAP

## ទស្សនៈវិស័យ

*"សង្គមមួយមានសន្តិភាព និងសមធម៌ជាទីដែលជនរងគ្រោះ និងក្រុមងាយរងគ្រោះទទួលបានការការពារ គ្រប់ទម្រង់ទាំងអស់នៃអំពើហឹង្សាលើយែនឌ័រ ការធ្វើអាជីវកម្ម និងការរំលោភបំពាន ជាពិសេសអំពើជួញដូរ អំពើអាជីវកម្ម ផ្លូវភេទ និងអាជីវកម្មលើកម្លាំងពលកម្ម ការរំលោភផ្លូវភេទ និងអំពើហឹង្សាក្នុងគ្រួសារ ។"*

## បេសកកម្ម

*"ការលើកស្ទួយការអនុវត្តន៍ច្បាប់ឱ្យមានប្រសិទ្ធិភាព និងប្រសិទ្ធិផលដោយសហការជាមួយវិស័យសុខុមាលភាពសង្គម វិស័យយុត្តិធម៌ និងសង្គមស៊ីវិលដើម្បីការពារជនរងគ្រោះ និងជនងាយរងគ្រោះពីអំពើហឹង្សា និងការកេងប្រវ័ញ្ច"។*

## គោលដៅរួមទូទៅ

*គោលដៅដ៏ចម្បងរបស់ LEAP គឺការពង្រឹងសមត្ថភាព និងប្រសិទ្ធិភាពនៃវិស័យអនុវត្តច្បាប់នៅក្នុងការទប់ស្កាត់ និងការចាប់ជនល្មើសទៅតុលាការ និងការសម្របសម្រួលសកម្មភាពទប់ស្កាត់ទាក់ទងនឹងអំពើធ្វើអាជីវកម្ម និងអំពើហឹង្សាទៅលើជនងាយរងគ្រោះ ជាពិសេសកុមារ និងស្ត្រី និងការការពារជនរងគ្រោះពីអំពើធ្វើអាជីវកម្ម និងការរំលោភបំពាន ។*

| គោលដៅយុទ្ធសាស្ត្រទី ១ | គោលដៅយុទ្ធសាស្ត្រទី ២ | គោលដៅយុទ្ធសាស្ត្រទី ៣ |
|---|---|---|
| *ទប់ស្កាត់រាល់ទម្រង់ទាំងអស់នៃអំពើហឹង្សាប្រឆាំងកុមារ និងក្រុមងាយរងគ្រោះដទៃ ទៀត ។* | *ការពារជនរងគ្រោះដោយសារអំពើហឹង្សាប្រឆាំងយែនឌ័រ អំពើធ្វើអាជីវកម្ម និងការរំលោភផ្លូវភេទ និងនាំជនប្រព្រឹត្តល្មើសឡើងតុលាការ ។* | *ពង្រឹងសមត្ថភាពស្ថាប័នក្រសួងមហាផ្ទៃដើម្បីគ្រប់គ្រងសកម្មភាពកម្មវិធី និងរៀបចំយន្តការសម្របសម្រួល សមស្របដែលគាំទ្រការអនុវត្តន៍សកម្មភាពកម្មវិធី ។* |

## យុទ្ធសាស្ត្រ

| | | |
|---|---|---|
| ■ ចូលរួមយ៉ាងសកម្មនៅក្នុងការរៀបចំតាក់តែងច្បាប់ គោលនយោបាយ និង | ■ រៀបចំប្រព័ន្ធដ៏សកម្មមួយសំរាប់ធ្វើអត្តសញ្ញាណកម្មជនរងគ្រោះ (ជំនួសឱ្យការរង់ចាំជនរង | ■ រៀបចំផែនការសកម្មភាពរយៈពេល៥ឆ្នាំដែលគួសបញ្ជាក់អំពីយុទ្ធសាស្ត្រអន្តរាគមន៏សំរាប់ការ អនុវត្តន៏ច្បាប់ដើម្បីផ្តល់សេវា |

គោលការណ៍ណែនាំស្តីអំពីអំពើហឹង្សា និង អំពើធ្វើអាជីវកម្ម និងការរំលោភផ្លូវភេទ

- រៀបចំសកម្មភាពបង្ការ ទប់ស្កាត់ និង សុវត្ថិភាពសហគមន៍ទាក់ទងនឹងអំពើហឹង្សាប្រឆាំងយែនឌ័រ អំពើធ្វើអាជីវម្ម និង ការរំលោភបំពាន។ ឧទាហរណ៍ ធ្វើជាជនបង្គោលនៅក្នុងសាលារៀន និង សហគមន៍ស្តីអំពីបញ្ហាសន្តិសុខ។

- សហការជាមួយក្រសួង និង ស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតដើម្បីរៀបចំការ បណ្តុះបណ្តាលសំរាប់មន្ត្រីនគរបាល យុត្តិធម៌ និង អាជ្ញាធរមូលដ្ឋានអំពីច្បាប់ និងគោលនយោបាយទាក់ទងនឹងអំពើ ជួញដូរ អំពើហឹង្សាក្នុងគ្រួសារ អំពើធ្វើអាជីវកម្មផ្លូវភេទ និងអាជីវកម្មពលកម្ម និងការរំលោភផ្លូវភេទ និង តួនាទីនៃការអនុវត្តន៍ច្បាប់ក្នុងការស៊ើបអង្កេតរាល់បទល្មើស

គ្រោះ)។

- មន្ត្រីអនុវត្តច្បាប់ត្រូវអនុវត្តប្រតិបត្តិការសង្គ្រោះប្រកបដោយប្រសិទ្ធិភាព និងប្រសិទ្ធិផល និង ធានារក្សាការសម្ងាត់នៃព័ត៌មានដែលផ្តល់ដោយជនរងគ្រោះ ។ល។

- មន្ត្រីអនុវត្តច្បាប់ត្រូវចាប់ខ្លួនជនល្មើស និងចារី និងត្រូវមានឯកសារជាចាំបាច់ (ឧទាហរណ៍ដីកាចាប់ខ្លួន)

- លើកកំពស់ដល់ប្រព័ន្ធបញ្ជូនជនរងគ្រោះទៅកាន់សេវាកម្មសុខភាព និងផ្នែកចិត្តសាស្ត្រ ។

- មន្ត្រីអនុវត្តច្បាប់ត្រូវប្រមូលភ័ស្តុតាងដោយហ្មត់ចត់ និងប្រុងប្រយ័ត្នដើម្បីដាក់បន្ទុកលើជនល្មើសពេលយកមកកាត់ទោស។

- LEAP

ការពារឱ្យបានកាន់តែប្រសើរដល់ជនរងគ្រោះនៃអំពើអាជីវកម្ម និងការរំ លោភផ្លូវភេទ អំពើជួញដូរមនុស្ស អំពើអាជីវកម្មតាមរយៈការស្នូមកូនចិញ្ចឹម អំពើអាជីវកម្មតាមរយៈអាពាហ៍ពិពាហ៍ និងអំពើហឹង្សាប្រឆាំងយែនឌ័រ ការសេពគ្រឿងញៀន និងកុមារទំនាស់នឹងច្បាប់។

- បង្កើតយន្តការសហការ និងកិច្ចសហប្រតិបត្តិការដោយផ្សារភ្ជាប់ជាមួយស្ថាប័នពាក់ព័ន្ធនានា និងក្រុមសង្គមស៊ីវិល (ជាពិសេសជាមួយក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច អតីតៈយុទ្ធជន និង យុវនីតិសម្បទា ក្រសួងសុខាភិបាល និងក្រសួងទេសចរណ៍ក៏ដូចជាស្ថាប័នអន្តរក្រសួង មានដូចជា គណៈកម្មាធិការជាតិ ក្រុមការងារខេត្តប្រឆាំងការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រុមប្រឹក្សាជាតិដើម្បីកុមារកម្ពុជា និង COMMIT (TIPSE, CNCC and COMMIT) ដើម្បី កែលំអរប្រសិទ្ធិភាពនៃការផ្តួចផ្តើមការអនុវត្តន៏ច្បាប់ និងជួយបង្កា និង ទប់ស្កាត់រាល់ទំរង់នៃអំពើហឹង្សា ប្រឆាំងយែនឌ័រ និង ការការពារជនរងគ្រោះ និងគ្រួសារ របស់ពួកគេ)។

- ធ្វើសុខដុមកម្ម និងស្តង់ដាសកម្មភាពបណ្តុះបណ្តាលសំរាប់

| | | |
|---|---|---|
| ទាំងនេះ ។<br><br>■ ចូលរួមនៅក្នុងយុទ្ធនាការបង្ការ និង ទប់ស្កាត់ផ្សេងៗដែលធ្វើឡើងដោយស្ថាប័ននានា ។<br><br>■ សម្របសម្រួលជាមួយនឹងស្ថាប័នផ្សេងទៀតក្នុងការរៀបចំ និងអនុវត្តន៏ការបណ្តុះបណ្តាលអំពីអាកប្បកិរិយា ការពារកុមារនិងក្រុមជនងាយរងគ្រោះ ។ | ■ ធានាដល់ការពង្រឹងវិធានការដើម្បីធានាអំពីការសម្ងាត់នៃព័ត៌មាន ។<br><br>■ ធានាថា ការស្តាប់ចម្លើយកុមារមេត្រីនឹងធ្វើឡើងដោយមន្ត្រីនគរបាលជាស្ត្រី និងដោយមានវត្តមានរបស់ឪពុកម្តាយ ឬអាណាព្យាបាលកុមារ ដោយប្រកាន់ខ្ជាប់គោលការណ៏ យែនឌ័រ ។ | មន្ត្រីអនុវត្តន៏ច្បាប់ និងអាជ្ញាធរ មូលដ្ឋាន ។ LEAP នឹង ***បង្កើតគណៈកម្មការពិនិត្យ និងរៀបចំការបណ្តុះបណ្តាលនគរបាល*** (Ad-hoc Police Training Steering Committee) ដើម្បីជួយដល់ការប្រមូល ការធ្វើសម្ភាសន៏ ការធ្វើ ចំណាត់ថ្នាក់ការរៀបចំឯកសារ និងការវាយតម្លៃរាល់ឯកសារបណ្តុះបណ្តាលស្តីពីការពង្រឹងការអនុវត្តន៏ច្បាប់ ។<br><br>■ ពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងលើកកំពស់ការគ្រប់គ្រងកម្មវិធី និងជំនាញបច្ចេកទេសដល់ក្រុម LEAP និង មន្ត្រីនគរបាលនៃនាយកដ្ឋានពាក់ព័ន្ធដែលធ្វើការក្រោមគំរោង LEAP ។<br><br>■ រៀបចំយុទ្ធសាស្ត្រដែលបង្កើនដល់ការងារជាក់ស្តែងនៃកម្មវិធី ។<br><br>■ ពង្រឹងទិន្ន័យការគ្រប់គ្រងករណីនៅក្នុខេត្តទាំងប្រាំពីរ (៧) ។<br><br>■ រៀបចំ ហើយអនុវត្តប្រព័ន្ធតាមដាន និងវាយតម្លៃដែលអនុម័តរួចដើម្បីគាំទ្រដល់ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការយុទ្ធសាស្ត្រ ។ LEAP នឹងសម្របសម្រួលដល់ការវាយ |

| | | |
|---|---|---|
| | | តម្លៃការអនុវត្តន៏ការងារប្រចាំ និងមន្ត្រី LEAP ។ |
| | | ■ សម្របសម្រួលដល់ការបង្កើតអង្គភាព ឬការិយាល័យជំនាញ " កុមារទំនាស់នឹងច្បាប់ " នៅ ក្នុងនាយកដ្ឋានមួយដែលស្ថិតនៅក្រោមអគ្គស្នងការនគរបាលជាតិ ឬនៅក្នុងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ។ |

## VII. ការរៀបចំផែនការយុទ្ធសាស្ត្រ LEAP ឆ្នាំ២០១១-២០១៥

ទីប្រឹក្សា LEAP នឹងសម្របសម្រួលការរៀបចំតាក់តែងផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំ ដើម្បីគាំទ្រដល់ក្របខ័ណ្ឌយុទ្ធសាស្ត្រ ឆ្នាំ២០១១-២០១៥ និង ផែនការសកម្មភាពឆ្នាំ២០១១។ ក្រុមនេះក៏នឹងរៀបចំសំណើគម្រោងមួយដែលដាក់បញ្ចូលនូវចំនួនការថវិកាដែលត្រូវការសម្រាប់ការអនុវត្តន៏ LEAP ដែលត្រូវដាក់ជូនម្ចាស់ជំនួយបច្ចុប្បន្ន និងម្ចាស់ជំនួយដែលរំពឹងទុកក្នុងពេលអនាគត ។

ក្នុងខណៈពេលដែលការរៀបចំផែនការយុទ្ធសាស្ត្រជាក់ស្តែងត្រូវចាប់ផ្តើមអនុវត្តនៅក្នុងខែមករា ឆ្នាំ២០១១ នោះសកម្មភាពទាំងឡាយដូចខាង ក្រោមត្រូវអនុវត្តន៏នៅក្នុងត្រីមាសចុងក្រោយនៃឆ្នាំ២០១០:

១. ពិនិត្យឡើងវិញ និងអនុម័តក្របខ័ណ្ឌយុទ្ធសាស្ត្រ ជាពិសេសរចនាសម្ព័ន្ធ LEAP និងផែនការសកម្មភាពឆ្នាំ ២០១១ ដោយក្រសួងមហាផ្ទៃតាមរយៈ**ឯកឧត្តម ព្រុំ សុខា។**

២. ដាក់ឈ្មោះថ្មីសំរាប់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការអនីតិជន និងអង្គភាពប្រឆាំងការជួញដូរមនុស្ស និងការអនីតិជនខេត្ត ( នាយកដ្ឋាន AHTJP និងអង្គភាព AHTJP ខេត្ត ) ។

*៣.* សេចក្តីសំរេចចិត្តស្តីអំពីការបង្កើត***អង្គភាព ការិយាល័យ ឬនាយកដ្ឋានជំនាញ កុមារទំនាស់នឹងច្បាប់*** នៅក្នុងក្រសួងមហាផ្ទៃ។

៤. ជ្រើសរើស ឬចាត់តាំងមន្ត្រីដើម្បីបំពេញមុខងារដូចមាននៅក្នុងរចនាសម្ព័ន្ធ LEAP ។ ដែលក្នុងនោះក៏ត្រូវមានមន្ត្រីដែលទទួលខុសត្រូវសកម្មភាពនានារបស់ LEAP នៅក្នុងនាយកដ្ឋាន AHTJP ថ្មី CID, DV, ប្រឆាំងគ្រឿងញៀន និងអង្គភាពផ្សេងៗទៀតដែលក្រសួងមហាផ្ទៃយល់ថាចាំបាច់សំរាប់ជាដៃគូរអនុវត្តន៏ជាមួយ LEAP ។ ហើយត្រូវមានសរសេរជាស្រេចនូវការរៀបរាប់អំពីការងារ តួនាទី និងភារៈកិច្ចសំរាប់មុខតំណែងនីមួយៗ ។

៥. សិក្ខាសាលាតម្រង់ទិសស្តីអំពីកម្មវិធី LEAP នឹងសម្របសម្រួលដោយទីប្រឹក្សាបច្ចេកទេសសំរាប់មន្ត្រី LEAP ទាំងអស់ ក៏ដូចជាសំរាប់នាយកដ្ឋាននានាក្រោមឱវាទក្រសួងមហាផ្ទៃ ។

៦. បទបង្ហាញអំពីក្រខ័ណ្ឌយុទ្ធសាស្ត្រ LEAP ឆ្នាំ ២០១១-២០១៥ នឹងបង្កើនការគាំទ្រច្រើនថែមទៀតពីម្ចាស់ជំនួយបច្ចុប្បន្ន និងការចចារជាមួយម្ចាស់ជំនួយសំខាន់ៗដើម្បីសុំការគាំទ្រដល់គោលការណ៏នេះ

៧. សម្របសម្រួលកម្មវិធីបិទបញ្ចប់គំរោង LEASETC ឧទាហរណ៏: របាយការណ៏បច្ចេកទេស និងហិរញ្ញវត្ថុ និងដំណើរការនៃការផ្ទេរមក LEAP រួមទាំងការបន្តជាថ្មីនូវអនុសារណៈ/កិច្ចព្រមព្រៀងស្តីពីការយោគយល់គ្នារវាងក្រសួងមហាផ្ទៃ និងម្ចាស់ជំនួយ និងការធ្វើអត្តសញ្ញាណកម្មការងារសំរាប់កម្មវិធី LEAP ។

៨. បទបង្ហាញអំពីក្របខ័ណ្ឌ LEAP ដល់ដៃគូររបស់រដ្ឋាភិបាល ( ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតៈយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងទេសចរណ៍ គណៈកម្មាធិការដឹកនាំការបង្ក្រាបការជួញដូរ ការរត់ពន្ធ ការកេងប្រវ័ញ្ចពលកម្ម និងការកេងប្រវ័ញ្ចផ្លូវភេទលើស្ត្រី និងកុមារ ក្រុមប្រឹក្សាជាតិដើម្បីកុមារ (STLS) COMMIT គណកម្មាធិការជាតិដើម្បីស្ត្រីកម្ពុជា ។ល។) ដៃគូរអភិវឌ្ឍន៍ និងក្រុមសង្គមស៊ីវិល ។

៩. រៀបចំ និងអនុម័តលើគំរោងសំណើសំរាប់ការពិភាក្សាជាមួយម្ចាស់ជំនួយបច្ចុប្បន្ន និងម្ចាស់ជំនួយដែលមានសក្ដានុពល ។

# ឧបសម្ព័ន្ធ ១

## បញ្ជីច្បាប់/ក្រមដែលពាក់ព័ន្ធស្តីពីការការពារក្រុមងាយរងគ្រោះ និងជនរងគ្រោះ ដោយអំពើរំលោភបំពាន អំពើហិង្សា និងអំពើធ្វើអាជីវកម្ម

**រដ្ឋសភាបានអនុម័តច្បាប់ និងក្រម ដូចខាងក្រោម :**

- ក្រមនីតិវិធីរដ្ឋប្បវេណីដែលប្រកាសអោយប្រើនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦
- ច្បាប់ស្តីពីឯកពន្ធភាពប្រកាសអោយប្រើនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៦
- ក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសអោយប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
- ក្រមរដ្ឋប្បវេណីប្រកាសអោយប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
- ច្បាប់ប្រឆាំងភេរវកម្មដែលប្រកាសអោយប្រើនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧
- នៅក្នុងខែសីហា ឆ្នាំ២០០៥ ច្បាប់ស្តីពីការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះត្រូវបានអនុម័តដោយរដ្ឋសភាជាតិ ហើយកាលពីពេលថ្មីៗនេះ ទីស្តីការគណៈរដ្ឋមន្ត្រី បានអនុម័តផែនការសកម្មភាពជាតិដើម្បីប្រយុទ្ធនឹងអំពើហឹង្សាប្រឆាំងស្ត្រីភេទ។
- ក្រមសីលធមិរបស់ចៅក្រម ព្រះរាជអាជ្ញា ត្រូវបានអនុម័តដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៧
- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវបានប្រកាសអោយប្រើកាលពីខែកុម្ភៈ ឆ្នាំ២០០៨
- ក្រុមការងារអន្តរក្រសួងជាន់ខ្ពស់មួយត្រូវបានបង្កើតឡើងនៅក្រោមក្រសួងមហាផ្ទៃដែលទទួលបន្ទុកបញ្ហាជួញដូរមនុស្ស
- សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំតុលាការ និងអយ្យការ
- សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា
- សេចក្តីព្រាងច្បាប់ស្តីពីបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងស្ថានភាពផ្ទាល់ខ្លួន
- សេចក្តីព្រាងច្បាប់ស្តីពីនីតិវិធីក្តីរដ្ឋប្បវេណីដែលមិនមែនបណ្តឹង
- ក្រមព្រហ្មទណ្ឌប្រកាសអោយប្រើនៅខែវិច្ឆិកា ឆ្នាំ២០០៩
- ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយខែមេសា ឆ្នាំ ២០១០